www.facebook.com/7khmer

# ប្រជុំពិធីបុណ្យ



ចាប - ពិន

## ពិធី ចម្រើនព្រះបរិត្ត

- បុណ្យសង្ឃទាន
- បុណ្យសង្ឃភត្ត
- បុណ្យមតកភត្ត
- បុណ្យសលាភភត្ត
- បុណ្យភេសជ្ជទាន
- បុណ្យកឋិន
- បុណ្យផ្កា
- បុណ្យបច្ច័យ៤
- វេរសាដក និង វេរគ្រប់យ៉ាង

បណ្ណាគារ រោងពុម្ព

២២៧.
១៣៦

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

ចំណេះដឹងគ្រប់វិនាទី

www.facebook.com/7khmer

២៧៩.
១៣៦

# ប្រជុំពិធីបុណ្យ

ឧត្តមប្រឹជា ចាប ពិន និពន្ធបណ្ឌិត

អតីតអធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

នៅពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ

រៀបរៀង

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

## សម្រាប់

ញាំងអ្នកអានឱ្យយល់កិច្ច រអាគធ្វើបុណ្យផ្សេងៗខ្លួនឯងបាន

បណ្ណាគារ

លេខ ៦៧ វិថីព្រះបាទចន្ទរាជា ភ្នំពេញ

ព.ស ២.៥០៧ គ.ស ១៩

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer

# បញ្ជីរាយមាតិកាធម៌

ទំព័រ


១- ពិធីចម្រើនព្រះបរិត្ត ............ ១
២- បុណ្យសង្ឃទាន ............ ១៨
៣- បុណ្យសង្ឃភត្ត ............ ២៦
៤- បុណ្យមតកភត្ត ............ ២៩
៥- បុណ្យសលាកភត្ត ............ ៣៣
៦- បុណ្យភេសជ្ជទាន ............ ៣៩
៧- បុណ្យកឋិន ............ ៤៣
៨- បុណ្យផ្កា ............ ៦០
៩- បុណ្យបច្ច័យ ៤ ............ ៧១
១០- បុណ្យវេរសាដកនៅរដូវចូលឆ្នាំ ............ ៧៧
១១- ពិធីវេរគ្រប់យ៉ាង ............ ៨២


www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer

# លំនាំដើម

អ្នកកាន់ព្រះពុទ្ធសាសនា គួរតែចេះដឹងក្បួនច្បាប់សម្រាប់ធ្វើបុណ្យទានផ្សេងៗគ្រប់គ្នា ប៉ុន្តែសព្វថ្ងៃនេះ អ្នកធ្វើបុណ្យទានខ្លះក៏ចេះដឹង ខ្លះក៏ពុំទាន់ចេះដឹងរបៀបធ្វើ របៀបសូត្រក្នុងពិធីបុណ្យទាំងពួងសព្វគ្រប់នៅឡើយ ដោយហេតុក្បួនតម្រាដែលស្តីពីពិធីបុណ្យទាន ពុំទាន់មានបោះពុម្ពផ្សាយគ្រប់គ្រាន់ទោះបីមានខ្លះក៏តិចតួច ហើយនៅរាត់រាយពីគ្នា ។

ព្រោះហេតុនេះ បានជាខ្ញុំរួបរួមពិធីបុណ្យទានផ្សេងៗ តាមគម្ពីរពុទ្ធសាសនាផង តាមប្រពៃណីខ្មែរដែលអ្នកប្រាជ្ញពីបុរាណលោកធ្លាប់ធ្វើជាគម្រូមកផង រៀបរៀងជាសៀវភៅ១ នេះឡើងឱ្យឈ្មោះថា«ប្រជុំពិធីបុណ្យ» ដោយមានពាក្យពន្យល់យ៉ាងងាយៗ អំពីពិធីបុណ្យផ្សេងៗ ទុកជាក្បួនច្បាប់សម្រាប់អ្នកធ្វើបុណ្យទានតទៅ តម្រូវតាមនិស្ស័យនៃអក្ខរជនដែលចេះអក្សរខ្មែរជាយូរមកហើយផង អនក្ខរជនដែលទើបនឹងបានរៀនចេះតាមព្រះរាជនយោបាយនៃសម្តេចឪផង ឱ្យអាចរៀន អាចចេះដឹងរបៀបធ្វើបុណ្យ របៀបសូត្រថ្វាយបង្គំព្រះ សមាទានសីលនិមន្តលោកសូត្រព្រះបរិត្ត និមន្តលោកសំដែងធម៌ ផ្សាយដំណឹងបុណ្យ សូត្រសុន្ទរកថា សូត្រវេរ សូត្របវារណា-បច្ច័យ សូត្រឧទ្ទិសផលជាដើម ក្នុងពិធីបុណ្យនោះៗ ផ្ទាល់ខ្លួនបានដោយស្រួល ព្រោះសៀវភៅនេះមានសព្វគ្រប់របៀបទាំងអស់ព្រមទាំងមានបាលីវេរគ្រប់យ៉ាង នៅខាងចុងបំផុតផង ។

ពុទ្ធបរិស័ទណាបានសៀវភៅនេះមួយទុកនៅជិតខ្លួន ហាក់ដូចបានគ្រូអាចារ្យដ៏ជំនាញម្នាក់នៅប្រចាំការ ជួយពន្យល់ជានិច្ចឱ្យអាចចេះដឹងកិច្ច

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ធ្វើបុណ្យទានផ្សេងៗ អោយត្រឹមត្រូវតាមច្បាប់ពុទ្ធសាសនាផង តាមប្រពៃ-ណីដែលបោរាណកបណ្ឌិតលោកធ្វើពីបុរាណកាលមកផង ។

ដូច្នេះ អស់លោកអ្នកពុទ្ធសាសនិកជនគ្រប់រូប គួរមានសៀវភៅនេះទុកជាអរិយទ្រព្យរបស់ខ្លួនរៀងខ្លួន ដើម្បីនឹងឆ្លៀតឱកាសសិក្សាអោយយល់កិច្ចធ្វើបុណ្យទានផ្សេងៗ ហើយអោយបានផលានិសង្សច្រើន តាមវិស័យចិត្តជាញាណសម្បយុត្តអសង្ខារិកគ្រប់គ្នាតទៅ ៖

ចាប- ពិន

អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



# ប្រជុំពិធីបុណ្យ

## ១. ពិធីចម្រើនព្រះបរិត្ត

កិច្ច «ចម្រើនព្រះបរិត្ត» ដែលអ្នកផងតែងហៅថា «សូត្របន្ត» នោះ ជាកិច្ចគឺពុទ្ធសាសនិកជនតែងធ្វើតាមពេលដែលត្រូវការ ដោយជឿថា ជាកិច្ចលំដោះគ្រោះថ្នាក់កំចាត់ចង្រៃ ចម្រើនសិរីសួស្តីជ័យមង្គល ។

ជំនឿនេះ ជាជំនឿចាស់អង្វែងណាស់មកហើយ របស់ពួកពុទ្ធបរិស័ទ ទាំងជាជំនឿមានគោលចារីកគ្រប់គ្រាន់ផងព្រោះមាននិទានក្នុងគម្ពីព្រះពុទ្ធសាសនាជាសំអាង គឺ :

និទានទី១ : ក្នុងធម្មបទដ្ឋកថាភាគីទី៤ ត្រង់រឿងអាយុវឌ្ឍនកុមារថា:

កាលព្រះបរមសាស្តាទ្រង់គង់ក្នុងអរញ្ញកុដិ មានព្រាហ្មណ៍ម្នាក់មានបុត្រតូច១ ត្រូវបព្វជិតខាងក្រៅព្រះពុទ្ធសាសនាទាយថា នឹងធ្វើការកិរិយាក្នុងថ្ងៃទី ៧ ។ មាតាបិតាតក់ស្លុតស្សួររកហេតុការពារមរណភ័យ ។ បព្វជិតនោះមិនប្រាប់ហេតុ គ្រាន់តែណែនាំអោយទៅទូលសួរព្រះបរមសាស្តា ។ មាតាបិតាបាននាំបុត្រនោះទៅគាល់ព្រះពុទ្ធអង្គ, ព្រះអង្គទ្រង់ព្យាករណ៍ដូចបព្វជិតនោះដែរ តែទ្រង់សំដែងហេតុការពារគឺទ្រង់អោយនិមន្តព្រះសង្ឃសូត្រព្រះបរិត្ត ជានិច្ចអស់ ៧យប់ ៧ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ស្តេចយាងទៅផ្ទះកុមារនោះផ្ទាល់ព្រះអង្គ ។ អមនុស្សដែលមកប៉ងបំផ្លាញជីវិតកុមារនោះឃើញព្រះអង្គក៏ចៀសចេញទៅ ។ ដល់ថ្ងៃទី ៨ អស់ខែត្រនៃបាបគ្រោះ, កុមារនោះក៏មានសិរីសួស្តីសុខចម្រើនឡើង អ្នកផងហៅថា «អាយុវឌ្ឍន-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


កុមារ»។ តពី នោះមក កុមារនោះរស់នៅយឺន យូរដល់ ១២០ឆ្នាំ ។

និទានទី ២ : ក្នុងធម្មបទដ្ឋកថា ភាគីទី ៧ ត្រង់រឿងអត្ថនោបុព្វកម្មថា:

កាលក្រុងវេសាលីកើតទុព្ភិក្ខភ័យ មនុស្សក្រៗស្លាប់ដោយអត់បាយអស់ជាច្រើន ចោលសាកសពពាសពេញទីក្រុង ។ ក្លិនបដិកូលនោះនាំឱ្យកើតអហិវាតករោគ មានពួកមនុស្សជាច្រើនចូលទីក្រុង ។ អ្នកនគរប្រជុំគ្នាកែខៃយ៉ាងណាក៏មិនរម្ងាប់សោះ ទើបព្រមព្រៀងគ្នាទៅអារាធនាព្រះបរមសាស្ដាដែលទ្រង់ប្រថាប់នៅឯក្រុងរាជគ្រឹះ។ គេរៀបចំព្រះនគរនឹងផ្លូវសម្រាប់ទ្រង់យាង ស្អាតល្អអស្ចារ្យ ចាំទទួលព្រះអង្គ ។ កាលទ្រង់យាងមកដល់ ទ្រង់ចាត់ព្រះអានន្ទឱ្យទៅរម្ងាប់អហិវាតករោគនោះ ។ ព្រះអានន្ទក៏បានត្រេចកាន់បាត្របាចទឹកជុំវិញកំពែងព្រះនគរ ដោយប្រកាសព្រះពុទ្ធគុណមានពាក្យថា: បណិធានតោ បដ្ឋាយ តថាគតស្ស ទស បារមិយោ។ល។ ជាដើម ។ ពួកមនុស្សដែលឈឺទៀបស្លាប់បានសះស្បើយ, ពួកបីសាចក៏រត់ខ្ចាត់ខ្ចាយអស់, ភ័យទាំងប៉ុន្មានក៏បានស្ងប់រម្ងាប់ដោយអំណាចព្រះបរិត្តដែលមានព្រះពុទ្ធគុណជាទីតាំង។ កាលដែលព្រះពុទ្ធអង្គទ្រង់យាងទៅនឹងយាងត្រឡប់មកវិញ ពួកមនុស្ស ទេវតា បានធ្វើសក្ការបូជា ជាមហោឡារិកកក្រើកអំពើកយ៉ាងក្រៃលែង ។

ព្រោះមាននិទានទាំងពីរនេះជាសំអាង បានជាយើងនិមន្តព្រះសង្ឃសូត្រព្រះសង្ឃសូត្រព្រះបរិត្តជាប់ជាប្រពៃណីរៀងមក ។

កិច្ចចម្រើនព្រះបរិត្ត តាមនិទានអាយុវឌ្ឍនកុមារក្ដី និទានអត្ថនោបុព្វកម្មក្ដី ឥតមានប្រាប់របៀបរៀបចំទេ តែតាមប្រពៃណីអំពីបុរាណមក ពុទ្ធ-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



បរិស័ទជាតិខ្មែរយើងតែងតែធ្វើដោយកាតព្វកិច្ចដូចខាងមុខ ៖

## កាតព្វកិច្ចនៃពិធីចម្រើនព្រះបរិត្ត

កិច្ចចម្រើនព្រះបរិត្ត មាន ៦ ថ្នាក់ គឺ

១. កិច្ចរៀបចំទីកន្លែង នឹងគ្រឿងសម្ភារៈ

២. កិច្ចនិមន្តព្រះសង្ឃ នឹងទទួលព្រះសង្ឃ

៣. កិច្ចនមស្សការព្រះរតនត្រ័យនឹងសមាទានសីល

៤. កិច្ចអារាធនាព្រះសង្ឃសូត្រព្រះបរិត្ត

៥. កិច្ចប្រគេនទេយ្យទាន

៦. កិច្ចឧទ្ទិសផល

កិច្ចទាំង ៦ ថ្នាក់នេះ មានបរិយាយដូចតទៅ ៖

## ថ្នាក់ទី ១ កិច្ចរៀបចំកន្លែងនឹងគ្រឿងសក្ការៈ

ព្រះបរិត្តចែកជា ២យ៉ាង គឺសត្តបរិត្ត ១យ៉ាង ទ្វាទសបរិត្ត ១យ៉ាង ។ ចាស់បុរាណហៅសត្តបរិត្តថា ធម៌សូត្រមន្តតូច ទ្វាទសបរិត្ត ថាធម៌សូត្រមន្តធំ ហើយកិច្ចសូត្រព្រះបរិត្តទាំង ២យ៉ាង នោះសោតក៏មាន ២យ៉ាង គឺសូត្រ រំដោះគ្រោះក្នុងពេលមានទុក្ខធុរៈ ១យ៉ាង, សូត្រកំសាន្តក្នុងពេលធ្វើបុណ្យទានផ្សេងៗ ១យ៉ាង ។ កិច្ចសូត្រទាំង ២យ៉ាង មានរបៀបប្លែកគ្នាបន្តិចបន្តួច ដូចរៀបរាប់ខាងមុខ ៖

កាលបើត្រូវការចម្រើនព្រះបរិត្តវេលាណា ទោះចម្រើនបែបណាក្តី គួរបើរៀបកំផុះសម្បែង ឬទីកន្លែង ដែលត្រូវសូត្រអោយមានរបៀបរៀបរយ

www.budmst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បើត្រូវការនៅផ្ទះ គប្បីរៀបចំត្រង់ល្វែងណាមួយជាល្វែងដ៏មានសេរី គឺរៀបតាំងអាសនៈព្រះពុទ្ធរូបដោយគ្រឿងសក្ការៈបូជា មានផ្កាផ្កាជាដើម ក្រាលកន្ទេល- កម្រាលខ្នើយ កន្តោរ ផ្តិលទឹកឆាន់ បើសូត្ររំដោះគ្រោះ ត្រូវមានផ្តិលទឹកព្រះបរិត្ត ដែលមានដាក់គ្រឿងអប់ឬ ផ្កាដ៏មានក្លិនក្រអូបក្នុងនោះ ហើយយកស្លឹកចេកមកមូរចងជាសំណុំប៉ុនមេដៃច្រៀកខាងចុងជាចម្រៀកៗ ដាក់តងលើមាត់ផ្តិលនោះ សម្រាប់ព្រះសង្ឃបាចទឹកព្រះបរិត្ត (១)នឹងមានដាក់អំបោះក្កុក (២) ១កម្រងក្នុងទឹកនោះផង សម្រាប់ព្រះសង្ឃស្រង់យកឱ្យសាមីខ្លួនអ្នកត្រូវសូត្រព្រះបរិត្តនោះ ពាក់ត្រចៀកនៅវេលាស្តាប់ព្រះបរិត្ត បើសូត្រកំសាន្តនៅពេលបុណ្យទានផ្សេងៗ មិនបាច់ពាក់អំបោះក្កុកទេ ហើយត្រូវរៀបគ្រឿងភេសជ្ជៈ មានទឹកតែ ស្ករ ស្លា បារីជាដើម សម្រាប់ព្រះសង្ឃឆាន់ នឹងមានរៀបស្លាធម៌ទ្រង់គ្រឿង ដែលគេយកកូនចេកមានស្លឹក ៣ ហៅកូនចេកកន្ទុយប្រើស ដោតបូស្សី ៣ ចម្រៀកពីខាងក្រោមធ្វើជើង ៣ ចម្រៀកពីខាងលើ ដោតស្លឹកម្លូ ៣សន្លឹក ដោតផ្កាឈើនៅគល់ធាងចេក-

---

(១) ក្នុងគម្ពីរព្រះវិន័យ មានពុទ្ធានុញ្ញាតជាពិសេសថា បើគ្រហស្ថនិមន្តឱ្យភិក្ខុធ្វើទឹកបរិត្ត ភិក្ខុគួរសូត្រព្រះបរិត្តធ្វើទឹកឱ្យគេបាន ។ ក្នុងគម្ពីរព្រះសូត្រមានពុទ្ធតម្រាស់ឱ្យព្រះអានន្ទជាអាទិកម្មបុគ្គលសូត្រព្រះបរិត្តបាចទឹករម្ងាប់ភ័យក្នុងក្រុងវេសាលី ។

(២) អំបោះក្កុកជាអំបោះមង្គល ២យ៉ាង មួយយ៉ាងគេគួចអំបោះធំគល់តូចចុងសម្រាប់សៀតនៅត្រង់ត្រចៀក មួយយ៉ាងគេចងអំបោះជារង្វង់ល្មមពាក់ក្បាលបាន សម្រាប់ពាក់ប្រហកនៅក្បាល ។ ទំនៀមរាស្ត្រគេសៀតអំបោះនេះនៅត្រចៀកក្នុងពេលស្តាប់ព្រះបរិត្តរំដោះគ្រោះ ទំនៀមព្រះរាជាទ្រង់ពាក់នៅព្រះសិរ ក្នុងពេលទ្រង់ព្រះសណ្តាប់លោកសូត្រភាណយក្ស (ត្រុដិសង្ក្រាន្ត) ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ចងបារីជាច្រើនតាមជួរឆាងចែកទាំង ៣នោះ ដាក់តាំងពីខាងមុខព្រះភក្ត្រព្រះសង្ឃជាសក្ការបូជាថ្វាយព្រះរតនត្រ័យ ។

ថ្នាក់ទី ២ កិច្ចនិមន្តព្រះសង្ឃនឹងទទួលព្រះសង្ឃ

ចំនួនព្រះសង្ឃដែលត្រូវនិមន្តមកសូត្រព្រះបរិត្ត ស្រេចនៅចិត្តអ្នកត្រូវការ ចង់និមន្តតែ ១រូប ឬតាំងពី ១ រូបឡើងទៅដល់រយរូបក៏បានរៀវតែពិធីមង្គលការដែលមានទំនៀមត្រូវធ្វើអ្វីៗជាគូៗ ទាំងអស់ដែលជាបញ្ហាមួយក្នុងពិធីនោះ ទើបគេនិមន្តកំណត់ចំនួនព្រះសង្ឃគឺ ៤រូប ៦រូប ឬ ៨រូប ជាគូៗ ។

កិច្ចនិមន្តព្រះសង្ឃដូចតទៅនេះ :

កាលបើបានរៀបចំផ្ទះសំបែង ឬទីកន្លែងសម្រាប់សូត្រព្រះបរិត្តរួចស្រេចហើយ ឧបាសកអ្នកត្រូវការនិមន្តព្រះសង្ឃសូត្រគប្បីទៅកាន់អារាមនមស្សការព្រះថេរៈជាចៅអធិការវត្តហើយទូលថេរដីកាថា :

ខ្ញុំព្រះករុណាសូមនិមន្តព្រះសង្ឃចំនួន.....(១)
រូបទៅសូត្រព្រះបរិត្ត..........
នៅផ្ទះ......នៅភូមិ......វេលា......ម៉ោង.....
នៅថ្ងៃ.....ខែ.....ឆ្នាំ.....នេះ ។

កាលព្រះសង្ឃនិមន្តមកដល់ផ្ទះ តាមវេលាដែលណាត់ហើយ, ឧបាសកគប្បីរង់ចាំទទួលព្រះសង្ឃនៅទ្វារភូមិ នឹងនៅជើងជណ្តើរផ្ទះ លើកដៃ

---

(១) ត្រង់ដែលចុចៗគ្រប់កន្លែង សម្រាប់បញ្ចូលចំនួនព្រះសង្ឃ ដែលមន្តសូត្រមន្ត ម៉ោងពេល នឹងថ្ងៃខែដែលត្រូវសូត្រតាមត្រូវការ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រណម្យដោយគោរព យកទឹកលាងព្រះបាទ យកសំពត់ស្អាតជូតព្រះបាទលោក, រួចនិមន្តលោកឡើងផ្ទះ, លុះលោកឡើងគង់លើអាសនៈហើយ គប្បីនាំគ្នាថ្វាយបង្គំលោកដោយគោរព រួចប្រគេនភេសជ្ជៈមានទឹកតែស្ករស្លាបារីជាដើម ឬភេសជ្ជៈក្រៅពីនេះដែលគួរតាមពុទ្ធានុញ្ញាតហើយដែលតាមមានតាមបាន ។

ថ្នាក់ទី ៣-កិច្ចនមស្សការព្រះរតនត្រ័យ សមាទានសីល

កាលគាត់ចែងភេសជ្ជៈប្រគេនលោក លោកទទួលឆាន់សព្វគ្រប់ហើយ ឧបាសកជាប្រធានក្នុងការសូត្រព្រះបរិត្តគប្បីផ្ដើមអុជទៀនធូបនៅទីទាំងពួងដែលគួរអុជ មានអាសនៈតាំងព្រះពុទ្ធរូបជាដើម ហើយផ្ដើមសូត្រនមស្សការព្រះរតនត្រ័យ ឧបាសកទាំងពួងគប្បីសូត្រជាមួយគ្នា ដោយបញ្ចេញសំឡេងលាន់ព្ធកងរំពងព្រមគ្នាជារយៈៗដូចទៅនេះ :

របៀបសូត្រ អ្នកនាំតាំងផ្ដើម ១ ឃ្លាខាងដើម, អ្នកទាំងអស់គ្នានាំគ្នាសូត្រតាំងពីឃ្លាបន្ទាប់តទៅ ដរាប់ដល់ចប់ គ្រប់លំដាប់ថ្នាក់ធម៌ដែលត្រូវសូត្រដូចខាងមុខ :

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ៣ដង

ប្រែថា កិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណាចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយគោរពចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ *ក្រាបថ្វាយបង្គំម្ដង* ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ អភិបូជយាមិ ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនឹងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណ-សម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ នឹងវិជ្ជា ៨ នឹងចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន លោក វិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាតិគុណរកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹង ទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា នឹងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យ

ត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ

ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គប្រកបព្រមហើយ ដោយគុណមានគុណថា អរហំ ជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

ក្រាបថ្វាយបង្គំម្តង ។

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ

ប្រែថា : ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង ហើយដោយល្អ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


(ធម្មោ ព្រះនពលោកុត្តរធម៌ មាន ៩ប្រការ គឺមគ្គ ៤ផល ៤និព្វាន១) សន្ទិដ្ឋិកោ ជាដើមគឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយជឿបុគ្គលដទៃនោះៗ ក៏ទេគឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌អោយនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ ឯហិបស្សិកោ ជាគួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលអោយចូលមកមើលបាន ឱបនយិកោ ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនគឺដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថាស្វាក្ខាតោជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច ធម្មំ ឥមេហិ សក្កាវេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

ក្រាបថ្វាយបង្គំម្តង ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុណេយ្យោ បាហុណេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា : សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនពលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាឋានក្សេមផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន ៤គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ នឹងសោតាបត្តិផលជាគូ ១ -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


សកទាគាមិមគ្គ នឹងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ នឹងអនាគាមិផល ជាគូ ១ អរហត្តមគ្គនឹងអរហត្តផលជាគូ ១ អដ្ឋ បុរិសបុគ្គលា បើរាប់រៀង ជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា បាហុណេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនឹងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនឹងផលនៃកម្ម ហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា សុបដិបន្នោជាដើមនោះដោយសិរសាគឺត្បូង តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះ-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ព្រះជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ក្រាបថ្វាយបង្គំម្តង ។

កាលនមស្សការព្រះរតនត្រ័យហើយ គេសមាទានសីល ៥ ឬ ៨ តាមពាមថ្ងៃដែលត្រូវការ ។ ទីនេះ ពោលចំពោះតែកិច្ច សីល ដូចតទៅនេះ÷

ពាក្យសមាទាននិច្ចសីល ៣ លើក :

លើកទី ១ ថា :

ឱកាស មយំ ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ យាចាម ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ យាចាម ។

ប្រែលើកទី ១ ថា :

សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ផ្សេងៗគ្នា ។ ជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បពិត្រព្រះ ។ ល ។ ផ្សេងៗគ្នា ។ ជាគម្រប់បីដងផង ។

កាលឧបាសកសុំសីលរួចហើយ ព្រះសង្ឃអ្នកសូត្រព្រះបរិត្ត លោកអោយព្រះត្រៃសរណគមន៍ នឹងសីល តាមលំដាប់តទៅថា :

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៣ដង ប្រែដូចបទ - នមស្សការខាងដើម ។

រួចលោកឱ្យព្រះត្រៃសរណគមន៍ថា :

ពុទ្ធំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭកជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

ប្រែថា : ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

### ថ្នាក់ទី ៤ កិច្ចអារាធនាព្រះសង្ឃសូត្រព្រះបរិត្ត

កាលសមាទានសីលរួចហើយ, ឧបាសកម្នាក់អារាធនាព្រះសង្ឃសូត្រព្រះបរិត្ត ៣លើក :

លើកទី ១ ថា :

វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។

វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។

ប្រែថា: សូមព្រះករុណាទាំងឡាយ ចម្រើននូវព្រះបរិត្ត ជាជ័យមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្ដីអន្តរាយទាំងពួង ដើម្បីនឹងញ៉ាំងនុក្ខញ៉ាំងភ័យរោគទាំងអស់ឱ្យវិនាសបាត់ទៅ ។

ចង់ប្រែរួមគ្នាដូច្នេះក៏បាន ចង់ប្រែរាយគ្នា ទុក្ខម្ដង ភ័យម្ដងរោគម្ដងក៏បាន ។

តពីនេះទៅ ព្រះសង្ឃអ្នកសូត្រព្រះបរិត្តលោកចាប់ផ្ដើមសូត្រសត្ថេប្រកាសអញ្ជើញទេវតាឱ្យមកស្ដាប់ព្រះបរិត្ត រួចលោកផ្ដើមសូត្រព្រះបរិត្តតទៅ តាំងពីដើមដរាបដល់ចប់តាមគួរដល់កាល, ឧបាសកនាំអង្គុយស្ដាប់ដោយគោរពរហូតដល់ចប់ ។

## ថ្នាក់ទី ៥ កិច្ចប្រគេនទេយ្យទាន

កាលចប់កិច្ចចម្រើនព្រះបរិត្តហើយ អ្នកម្ចាស់ទានគប្បីបង្អោនទេយ្យវត្ថុទៅប្រគេនលោក ។ ការប្រគេននោះ ភេសជ្ជៈមានតែស្លា ជាដើម គប្បីប្រគេនផ្ទាល់ដៃ ចំណែកហិរញ្ញវត្ថុ គប្បីប្រគេនដោយបវារណា គឺដឹកលុយប្រាក់តាមចំនួនដែលត្រូវការប្រគេនប៉ុន្មាន ១អង្គនោះ លើជើងពាន ១ ចំពោះព្រះភក្ត្រព្រះសង្ឃ ហើយលើកជើងពាននោះឡើងបវារណា ដោយកប្បិយវោហារដូចនេះ :



www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


## ពាក្យបវារណាបច្ច័យ

បពិត្រព្រះករុណាដ៏ចម្រើន យើងខ្ញុំទាំងឡាយសូមបវារណាប្រគេននូវបច្ច័យ ៤គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈចំនួន. .(១) រៀល (១ព្រះអង្គ (២) ) ។ យើងខ្ញុំទុកដាក់បច្ច័យទាំងនេះនៅដៃវេយ្យាវច្ចករឈ្មោះ(៣) នេះ, បើព្រះករុណាត្រូវការបច្ច័យណាមួយ វេលាណា សូមឱ្យវេយ្យាវច្ចករនេះ ចាត់ចែងប្រគេនដរាបដល់អស់បច្ច័យនេះ ដើម្បីសេចក្ដីសុខសេចក្ដីចម្រើនដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែង ។

### ថ្នាក់ទី ៦ កិច្ចឧទ្ទិសផល

កាលប្រគេនទេយ្យទាន នឹងបវារណាចតុប្បច្ច័យហើយព្រះសង្ឃលោកសូត្រអនុមោទនា ចប់អនុមោទនាហើយ, ឧបាសកសូត្រយំកិញ្ចិឧទ្ទិសផលដូចតទៅនេះ÷

យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ កតំ ។
យេ សត្តា សញ្ញិនោ អត្ថិ យេច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ ។

---

(១) ត្រង់នេះ ត្រូវបញ្ចូលចំនួនបច្ច័យ ។
(២) ត្រង់នេះបើលោកតែ ១ អង្គត្រូវថា ដល់ព្រះករុណាម្ចាស់ ។
(៣) ត្រង់នេះ ត្រូវបញ្ចូលឈ្មោះអ្នកដែលទទួលទុកដាក់បច្ច័យរបស់លោក ។
(៤) ពាក្យបវារណានេះប្រើបានទូទៅក្នុងពិធីបុណ្យផ្សេងៗ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ ។
សព្វេលោកម្ហិ យេសត្តា ជីវន្តាហារហេតុកា
អនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

ប្រែថា : យំកិញ្ចិកុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសល ឯណាមួយដែលខ្ញុំគប្បីធ្វើ កាយេន វាចាមនសា ដោយទ្វារទាំង៣គឺកាយ វាចាចិត្ត តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានត្រៃត្រឹង្សសួគ៌បាន យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយឯណា គឺមនុស្សទេវតាព្រហ្មដែលជាសត្វមានសញ្ញាក្តី យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយ ទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅនេះចុះ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះចូរឱ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យទៅនេះចុះ យេ ច តត្ថ ន ជានន្តិ មួយយ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹង នូវបុណ្យដែលខ្ញុំបានធ្វើហើយ -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ទេវា គន្ធា និវេទយុំ សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយ ផលបុណ្យនោះដល់អ្នកទាំងឡាយៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យនោះចុះ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា សត្វទាំងឡាយ ឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយ ទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញិទ្ធិតាមចិត្តដែលខ្ញុំ ឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

*ចប់ពិធីចម្រើនព្រះបរិត្តប៉ុណ្ណោះ ។*

## ២-ពិធីបុណ្យសង្ឃទាន

### ទាន ២ ចំពូក

១- ទានដែលប្រគេនចំពោះភិក្ខុឬសាមណេរ១រូបៗតាម ចិត្តស្រឡាញ់ ហៅថា បាដិបុគ្គលិកទាន

២- ទានដែលប្រគេនចំពោះព្រះសង្ឃ គឺភិក្ខុ តាំងពី ៤ រូបឡើងទៅ ហៅថា សង្ឃទាន ។

បណ្តាទានទាំង២ចំពូក សង្ឃទាន មានផលានិសង្ស ច្រើនលើសលុបជាងបាដិបុគ្គលិកទាន ព្រោះជាទានដ៏ឧត្តមនាំឱ្យសង្ឃ ក្នុងព្រះពុទ្ធសាសនាមានសាមគ្គីគ្នា ជាហេតុនាំឱ្យព្រះពុទ្ធសាសនាមានសេចក្តីរុងរឿង ។

ទីនេះ សូមអធិប្បាយពន្យល់តែចំពោះសង្ឃទាន មួយចំពូកដូចតទៅ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


នេះ ÷

## សង្ឃទាន ៧ ប្រភេទ

សម័យពុទ្ធកាលទាយកធ្វើសង្ឃទានមាន ៧ ប្រភេទគឺ :

១- ទានប្រគេនចំពោះភិក្ខុសង្ឃ នឹងភិក្ខុនីសង្ឃ មានព្រះពុទ្ធជាប្រធាន

២- ទានប្រគេនចំពោះ ឧភតោសង្ឃ ក្នុងកាលដែលព្រះតថាគត បរិនិព្វានហើយ

៣- ទានប្រគេនចំពោះភិក្ខុសង្ឃ

៤- ទានប្រគេនចំពោះភិក្ខុនីសង្ឃ

៥- ទានប្រគេនចំពោះភិក្ខុ ដែលគេនិមន្តយកអំពីសំណាក់ឧភតោសង្ឃ

៦- ទានប្រគេនចំពោះភិក្ខុ ដែលនិមន្តយកអំពីសំណាក់ភិក្ខុសង្ឃ

៧- ទានធ្វើដោយសុំសង្ឃអោយបញ្ជូនភិក្ខុ ឬ សាមណេររូបណាមួយនៅឯផ្ទះរបស់ខ្លួន ហើយប្រគេនទេយ្យទានចំពោះភិក្ខុ ឬ សាមណេររូបនោះ ដោយឧទ្ទិសចំពោះសង្ឃ(១) ។

---

(១) រឿងនេះ មានពិស្តារក្នុងមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រ គាថាទី៥ ត្រង់ទានកថា។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



សម័យបច្ចុប្បន្ន ទាយកធ្វើសង្ឃទានមិនបានគ្រប់ទាំង ៧ ប្រភេទទេ បានតែចំពោះភិក្ខុសង្ឃ ១ ប្រភេទ ព្រោះពេលនេះគ្មានភិក្ខុនី គឺទាយកធ្វើ បានតែចំពោះភិក្ខុ ឬសាមណេរដែលសង្ឃចាត់មកតាមពាក្យសុំរបស់ខ្លួន នឹងចំពោះព្រះភត្តព្រះពុទ្ធបដិមាករសួងព្រះពុទ្ធអង្គប៉ុណ្ណោះ តែការធ្វើសង្ឃ ទានដល់ភិក្ខុសង្ឃដែលមានព្រះពុទ្ធរូបជាប្រធាន ដូច្នេះក៏អនុលោមចូលក្នុង ការធ្វើសង្ឃទានមានព្រះពុទ្ធផ្ទាល់ព្រះអង្គជាប្រធានដែរ ព្រោះត្រូវតាម ប្រភេទទី២ នៃសង្ឃទាន ដូចបានចែងក្នុងមាតិកាខាងដើម ។

## អង្គនៃសង្ឃទាន

អដ្ឋកថាទក្ខិណាវិភង្គសូត្រ មានចែងថា :

អង្គនៃសង្ឃទាន មាន ២ គឺ

១- ទាយកបានសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២- កាលលោកបដិគ្គាហកៈនិមន្តមក បានតាំងចិត្តពោះសង្ឃ ។

ការធ្វើសង្ឃទាន លុះតែប្រកបដោយអង្គទាំង២នេះ ទើបឈ្មោះថាជា សង្ឃទានពេញលក្ខណៈ ។ បណ្តាអង្គទាំង២នេះ អង្គទី១ ទាយកងាយធ្វើ បាន ។ ឯអង្គទី២ទាយកមិនងាយធ្វើបានទេ ព្រោះការធ្វើសង្ឃទានទាយកត្រូវ ចូលទៅវត្តទូលសុំសង្ឃអំពីភិក្ខុជាចៅអធិការ ឬជាភត្តុទ្ទេសក៏ថា «សូម លោកម្ចាស់មេត្តា ចាត់ព្រះថេរៈ១អង្គ អំពីសង្ឃឱ្យទៅទទួលសង្ឃទានឯផ្ទះ ខ្ញុំព្រះករុណា» ។ កាលទាយកសុំព្រះថេរ ហើយបើបែរជាបានសាមណេរមក វិញ ក៏អាក់អន់ចិត្តដោយគ្រាន់តែនឹកអន់ចិត្តថា «ឱ ! អញបានសមណេរ»

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



ឱ្យត្រឹមត្រូវតាមរបៀបសង្ឃទាន ទើបបានជាសង្ឃទានពេញលក្ខណៈ ។ ការសុំនិមន្តបដិគ្គាហកៈអំពីសង្ឃនោះ ទោះបីសុំនិមន្តប៉ុន្មានអង្គក៏បាន តាមត្រូវការ ហើយទូលសុំនិមន្តចំពោះតែថ្ងៃដែលត្រូវការធ្វើក៏បាន ទូលសុំនិមន្តតែម្តង ទុកធ្វើរាល់ថ្ងៃសីលជាយូរថ្ងៃខែឆ្នាំតទៅ គឺថាដល់ថ្ងៃសីលកាលណាឱ្យលោកនិមន្តទៅ មិនបាច់ទាយកទៅនិមន្តទៀតក៏បាន ។ ហើយការសុំនិមន្តនោះ ត្រូវទូលសុំអំពីលោកគ្រូចៅអធិការវត្ត ឬអំពីភិក្ខុជាភត្តុទ្ទេសក៍ (លោកអ្នកចាត់ការរៀងភត្ត ដែលជំនុំសង្ឃតាំងឱ្យជាអ្នកចាត់ ) ឱ្យលោកចាត់ឱ្យក៏បាន ។ ម្ចាស់ទានមិនត្រូវនិមន្តផ្ទាល់ខ្លួន ចំពោះភិក្ខុ ឬសាមណេរណាមួយតាមដែលខ្លួនស្គាល់ ឬស្រឡាញ់ទេ បើនិមន្តដូច្នោះ ទាននោះនឹងទៅជាបាដិបុគ្គលិកទាន ។ ឯពាក្យទូលសុំនិមន្តបដិគ្គាហកៈអំពីសង្ឃនោះ ទាយកត្រូវទូលសុំ និមន្តថា «សូមលោកម្ចាស់មេត្តាចាត់ភិក្ខុ (ឬសាមណេរ) ១រូប (ឬ២រូប) ណាមួយ, ឱ្យទៅទទួលសង្ឃទាន នៅឯផ្ទះខ្ញុំព្រះករុណាក្នុងថ្ងៃ(១) នេះវេលា ព្រឹកម៉ោង ។

## ថ្នាក់ទី ២ កិច្ចរៀបចំទីសេនាសនៈ នឹងទេយ្យទាន :

ក្រោយពីសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃហើយ ក្នុងពេលដែលត្រូវការ ត្រូវរៀបទីសេនាសនៈ ជាកន្លែងដែលត្រូវធ្វើសង្ឃទាន គឺរៀបតាំងអាសនៈព្រះពុទ្ធរូប មានគ្រឿងសក្ការៈបូជា រៀបក្រាលកន្ទេល កម្រាលខ្នើយ កន្ទោរ ផ្តិលទឹក ថូផ្កា ហើយនឹងគ្រឿងភេសជ្ជៈ មានទឹកតែ ស្ករ ស្លា

(១)ត្រង់ចុចៗនេះ ត្រូវបញ្ចូលឈ្មោះថ្ងៃនឹងម៉ោងតាមដែលត្រូវការ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



ម្ហូ បារី ជាដើម ដាក់រៀបរយ តាមជួរកន្ទេលដែលក្រាលកម្រាលយ៉ាងស្អាត សម្រាប់ប្រគេនលោកឆាន់ ។

## ថ្នាក់ទី ៣ កិច្ចទទួលលោកបដិគ្គាហកៈដែល សង្ឃចាត់ឱ្យមក

កាលភិក្ខុ ឬសាមណេរ ជាបដិគ្គាហកៈដែលសង្ឃចាត់និមន្តមកដល់គ្រឹះស្ថានរបស់ខ្លួនហើយ ទាយកជាម្ចាស់ទានឬអ្នកតំណាងម្នាក់ គប្បីក្រោកចេញទៅទទួលលោកនៅត្រង់មុខផ្ទះ ឬទ្វាររបងភូមិ និមន្តលោកចូលផ្ទះ លុះលោកនិមន្តដល់ជណ្តើរផ្ទះ ត្រូវយកទឹកលាងព្រះបាទលោក ហើយជូតដោយសំពត់ស្ងួតស្អាត ឬគ្រាន់តែយកសំពត់ស្អាតជូតព្រះបាទលោកឱ្យជ្រះធូលីក៏បាន ហើយនិមន្តលោកចូលទៅគង់លើអាសនៈ ដែលរៀបចំហើយដោយរៀបចំហើយដោយប្រព្រៃនោះ ។

## ថ្នាក់ទី ៤ កិច្ចនមស្សការព្រះរតនត្រ័យ នឹងសមាទានសីល

លុះលោកជាបដិគ្គាហកៈ គង់លើអាសន ស្រួលបួលហើយត្រូវនាំគ្នាថ្វាយបង្គំលោកដោយគោរព ហើយចូលទៅប្រគេនភេសជ្ជៈដល់លោក រួចត្រូវឱ្យជួសដោះចង្ហាន់ដាក់ចានធំៗ សម្រាប់រាប់បាត្រ ព្រមទាំងជួសបង្អែមចំអាបដាក់ក្នុងចានស្រាក់សម្រាប់ប្រគេនលោក ក្នុងពេលវេរបាលីហើយវត្ថុទាំងនោះត្រូវយកមកដឹកល់ចំពោះព្រះភក្ត្រលោកជាបដិគ្គាហកៈ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ ជាប្រមុខក្នុងទីនោះ ហើយនាំគ្នាអុជធៀនធូប

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


រួចសូត្រថ្វាយបង្គំព្រះ តាមបែបសង្ខេបក៏បាន វិត្ថារក៏បាន ចប់ហើយ អារាធនានិច្ចសីលឬឧបោសថសីលតាមថ្ងៃដែលធ្វើ គឺបើធ្វើក្រៅពីថ្ងៃសីល ត្រូវអារាធនានិច្ចសីល បើធ្វើត្រូវលើថ្ងៃសីលគប្បីអារាធនាឧបោសថសីល (១) ។

ថ្នាក់ទី ៥ កិច្ចវេរសង្ឃទាននឹងប្រគេនទេយ្យទាន

លុះសមាទានសីលចប់ហើយ ត្រូវនាំគ្នារាប់បាត្រៗហើយអ្នកដែលចេះចាំបាលីវេរសង្ឃទាន ត្រូវកាន់បាត្រចង្ហាន់ អ្នកក្រៅពីនេះ ត្រូវកាន់បរិក្ខារឯទៀតខ្លះ លើកដៃប្រណមឡើងរួចនាំសូត្រវេរដូចតទៅនេះ ។

មុនដំបូងត្រូវសូត្រនមស្សការ៣ដងថា :

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ហើយសូត្របាលីវេរ ៣ លើក :

លើកទី ១ ថា :

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សជេ្ចត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយាទីនិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ល។ សុខាយ ។

---

(១) បាលីនមស្សការ នឹងសមាទានសីល ត្រូវសូត្រតាមដែលមានក្នុងពិធីចម្រើនព្រះបរិត្តខាងដើមនៃសៀវភៅនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ល។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនហើយ យើងខ្ញុំទាំងឡាយបានតាក់តែង នូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវវត្ថុទាំងឡាយមានបង្អែម នឹងចំអាបជាដើមនោះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃង ។ល។ ទៅហោង ។ អស់វារៈពីរដងផង

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លៃង ។ល។ ទៅហោង ។ អស់វារៈបីដងផង

កាលវេរដោយវាចាហើយ គប្បីលើកចង្ហាន់នោះប្រគេនលោកដោយកាយទៀត, តែចំណែកខាងបក្ខ័យ គប្បីបវារណាដោយវាចាតែមួយយ៉ាងមិនបាច់ប្រគេនដោយកាយទេ ដូចរោនចែងទុកជាគម្រូ ក្នុងពិធីចម្រើនព្រះវិត្តងណោះ សព្វគ្រប់ស្រាប់ សូមយកតាមនោះចុះ ។

## ថ្នាក់ទី ៦ - កិច្ចឧទ្ទិសផល :

កាលលោកទទួលចង្ហាន់នឹងទេយ្យទានហើយ លោកសូត្រភត្តានុ -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


មោទនាៗចប់ហើយ ឧបាសកឧបាសិកាតប្បើនាំគ្នាសូត្រយំកិញ្ចិឧទ្ទិសផល(១) ជាកិច្ចបញ្ចើយបុណ្យ ។

ចប់ពិធីបុណ្យសង្ឃទានត្រឹមប៉ុណ្ណោះ ។

## ៣- ពិធីបុណ្យសង្ឃភត្ត

កុសលកិច្ចដែលធ្វើដោយវេរចង្ហាន់ប្រគេនភិក្ខុ តាំងពី៤រូបឡើងទៅ ហៅថា «បុណ្យវេរសង្ឃភត្ត» ឬថា «បុណ្យវេរចង្ហាន់សង្ឃ» ឬក៏ហៅថា «បុណ្យនិមន្តលោកឆាន់» ក៏បាន ។

### កាតព្វកិច្ចនៃសង្ឃភត្តៈ

បុណ្យវេរសង្ឃភត្ត នឹងធ្វើនៅទីវត្តក៏បាន នៅផ្ទះរបស់ទាយកក៏បាន ។ បុណ្យនេះ ទោះធ្វើនៅវត្តក្តី នៅផ្ទះក្តី មានកាតព្វកិច្ចត្រូវចាត់ចែងជា ៦ ថ្នាក់ ដូចគ្នាគឺ :

១- កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២- កិច្ចរៀបចំទីសេនាសនៈនឹងទេយ្យទាន

៣- កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់មក

៤- កិច្ចនមស្សការព្រះរតនត្រ័យនឹងសមាទានសីល

៥- កិច្ចវេរសង្ឃភត្តនឹងប្រគេនទេយ្យទាន

(១) ធម៌យំកិញ្ចិឧទ្ទិសផល មាននៅក្នុងពិធីចម្រើនព្រះបរិត្តឯណោះហើយ សូមយកតាមនោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៦- កិច្ចឧទ្ទិសផល

បណ្ដាកិច្ចទាំង៦ថ្នាក់នេះ កិច្ចថ្នាក់ទី ២-៣-៤ នឹង ៦ ដូចគ្នានឹងសង្ឃទាន សូមយកតាមបែបសង្ឃទាននោះចុះ ។

ក្នុងទីនេះសូមពណ៌នាតែចំពោះកិច្ចថ្នាក់ទី ១ និងទី ៥ ដែលប្លែកពីសង្ឃទានបន្តិចដូចតទៅនេះ :

ថ្នាក់ទី ១ កិច្ចនិងនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

ទាយកត្រូវសុំនិមន្តលោកបដិគ្គាហកៈ ចំនួន ៤រូបឡើងទៅអំពីលោកជាចៅអធិការឬជាភត្តុទ្ទេសក៍ ( អ្នកសំដែងភត្ត ) តម្រូវតាមពាក្យថាសង្ឃភត្ត ។

ថ្នាក់ទី ៥ កិច្ចវេរសង្ឃភត្តនឹងប្រគេនទេយ្យទាន :

ដល់ពេលវេរ គប្បីវេរ ៣ លើក :

លើកទី ១ ថា :

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិកោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស ឥមំ (សង្ឃភត្តំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោ-ទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ។

លើកទី ២ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ទុតិយម្បិ អយំ នោ ភន្តេ ។ ល ។ បមុញ្ចន្តុ ។

លើកទី ៣ ថា :

តតិយម្បិ អយំ នោ ភន្តេ ។ ល ។ បមុញ្ចន្តុ ។

ប្រែលើកទី ១ ថា :

- បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ, វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌, បានមកដោយធម៌, កើតឡើងដោយធម៌, យើងខ្ញុំទាំងឡាយ, សូមឧទ្ទិសចំពោះ, ដល់លោកអ្នកដ៏មានគុណទាំងឡាយមានមាតានឹងបិតាជាដើម, យើងខ្ញុំទាំងឡាយ, វេរ (នូវសង្ឃភត្ត) នេះ, ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃ, មានព្រះពុទ្ធជាប្រធាន, សូមលោកអ្នកដ៏មានគុណទាំងឡាយ, មានមាតានឹងបិតាជាដើមនោះ, សំគាល់ (នូវសង្ឃភត្ត) នេះ, ថាដូចជារបស់នៃខ្លួន, ហើយសូមអនុមោទនាយកចុះ, លុះអនុមោទនារួចហើយ, សូមឱ្យរួចលំដោះ, ចាកទុក្ខទាំងពួង, ឱ្យបានសម្រេច ដោយសម្បត្តិទាំងឡាយ៣ប្រការ, គឺសម្បត្តិមនុស្ស១, សម្បត្តិទេវតា១, សម្បត្តិព្រះនិព្វាន១, ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនមកមិនដាច់នេះហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ល។ នេះហោង ។ អស់វារៈជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



បពិត្រព្រះ ។ល។ នេះហោង ។ អស់វារៈជាគម្រប់បីដងផង ។

វេរចប់ហើយ ត្រូវប្រគេនចង្ហាន់ ព្រមទាំងទេយ្យទាន(១) ដល់ព្រះសង្ឃៗ ទទួលហើយ លោកអនុមោទនាតាមគួរដល់ទាននឹងកាលវេលា ។

ថ្នាក់ទី ៦ កិច្ចឧទ្ទិសផល

កាលប្រគេនចង្ហាន់ ព្រមទាំងទេយ្យទានដល់លោកៗអនុមោទនាគប្បីហើយសូត្រយកិច្ចឧទ្ទិសផល ជាកិច្ចបង្ហើយបុណ្យ ។

*ចប់ពិធីបុណ្យវេរសង្ឃភត្តត្រឹមប៉ុណ្ណេះ ។*

## ៤- ពិធីបុណ្យមតកភត្ត

កិច្ចបុណ្យដែលទាយកធ្វើដោយវេរចង្ហាន់ ប្រគេនព្រះសង្ឃឧទ្ទិសផលបញ្ជូនទៅបុគ្គលដែលស្លាប់ ហៅថា «បុណ្យវេរមតកភត្ត» តែតាមទម្លាប់អ្នកស្រុកហៅថា «បុណ្យដារ» ព្រោះសម័យបុរាណ ព្រះសង្ឃដែលនិមន្តមកសូត្រក្នុងពេលនោះ តែងសូត្រធម៌ពិស្ដារ គឺបាលីព្រះអភិធម្ម៧ គម្ពីរបែបវែងដែលចាស់ៗតែងហៅកាត់យកតែអក្សរ ១ តួខាងចុងថា «ធម៌ដារ» គឺបុណ្យដារបញ្ជូនផលទៅឱ្យខ្មោច ។

បុណ្យនេះគេតែងធ្វើនៅពេលដែលមានបុគ្គលជាញាតិមាន មាតាបិតាជាដើម ស្លាប់រវាង ១ថ្ងៃ ឬ ២ថ្ងៃម្ដង ៧ថ្ងៃម្ដង ១០០ថ្ងៃម្ដង ហើយនឹងពីរនោះពល់ឆ្នាំទៀត គឺធ្វើ១ខួបម្ដង ចំលើថ្ងៃខែដែលបុគ្គលនោះស្លាប់ ។

---

(១) ចំណែកខាងបច្ច័យគប្បីបវារណាដោយវាចាតាមពិធីបវារណាក្នុងពិធីចម្រើនព្រះបរិត្តរួចហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


## កាតព្វកិច្ចនៃមតកភត្ត

កិច្ចដែលត្រូវធ្វើបុណ្យនេះចាត់ជា ៦ថ្នាក់ គឺ :

១- កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២- កិច្ចរៀបចំទីសេនាសនៈនឹងទេយ្យទាន

៣- កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់មក

៤- កិច្ចនមស្សការព្រះរតនត្រ័យនឹងសមាទានសីល

៥- កិច្ចវេមតកភត្តបង្សុកូល នឹងប្រគេនទេយ្យទាន

៦- កិច្ចឧទ្ទិសផល

បណ្តាកិច្ចទាំង ៦ ថ្នាក់នេះ ថ្នាក់ទី ១. ៣. ៤. នឹង ៦ ដូចកិច្ចក្នុងពិធីបុណ្យសង្ឃទាន ប្លែកតែត្រង់ថ្នាក់ទី ២ នឹងទី ៥ ។ ដូច្នេះថ្នាក់ទី ១ ៣. ៤ នឹង ៦ សូមយកតាមពិធីបុណ្យសង្ឃទាននោះចុះ ។ ទីនេះ សូមពណ៌នាចំពោះតែថ្នាក់ទី ២ នឹងទី ៥ដូចតទៅនេះ

### ថ្នាក់ទី ២ កិច្ចរៀបចំទីសេនាសនៈ នឹងទេយ្យទាន

បើបុគ្គលដែលត្រូវឧទ្ទិសផលទៅនោះ ទើបនឹងស្លាប់ ទើបនឹងធ្វើឈាបនកិច្ចថ្មីៗ ក្រោយពីពេលរៀបចំទីសេនាសនៈ នឹងភេសជ្ជៈរួចហើយ ត្រូវយកធាតុដែលដាក់ក្នុងកោដ្ឋដឹកល់នៅមុខព្រះភក្ត្រព្រះសង្ឃ នឹងយកចង្ហាន់ព្រមទាំងទេយ្យទាន ដែលត្រូវប្រគេនលោកពេលនោះ មកដឹកល់ទុកនៅមុខលោក ដើម្បីវេរប្រគេនលោក ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



## ថ្នាក់ទី ៥ កិច្ចទេរមតកភត្ត បង្សុកូល នឹងប្រគេនទេយ្យទាន

ដល់ពេលវេរ ត្រូវវេរដោយបាលី នឹងប្រែ ៣ លើក ៖

លើកទី ១ ថា ៖

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ, ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (មតកភត្តំ) (១) សបរិក្ខារំ ពុទ្ធប្បមុខស្ស ទេម តេ គុណវន្តាទយោ ឥមំ (មតកភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ។

លើកទី ២ ថា ៖

ទុតិយម្បិ អយំ នោ ភន្តេ ។ ល ។ បមុញ្ចន្តុ ។

លើកទី ៣ ថា ៖

តតិយម្បិ អយំ នោ ភន្តេ ។ ល ។ បមុញ្ចន្តុ ។

ប្រែលើកទី ១ ថា ៖

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មាន-

---

១) បាលីក្នុងវង់ក្រចកនេះ ត្រូវផ្លាស់តាមឈ្មោះភត្តដែលត្រូវការធ្វើ ។

www.budhist.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


មាតានឹងបិតាជាដើម យើងខ្ញុំទាំងឡាយវេរ (នូវមតកភត្ត) (១) នេះ ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានឹងបិតាជាដើមនោះ សំគាល់ (នូវមតកភត្ត)នេះថាដូចជារបស់នៃខ្លួនហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមអោយរួចរំដោះចាកទុក្ខទាំងពួងអោយបានសម្រេចដោយសម្បត្តិទាំង ៣ប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហួរជូនមកមិនដាច់នេះហោង ។

ប្រែលើកទី ២ ថា :

ពុត្រព្រះ ។ ល ។ នេះហោង, ជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ ល ។ នេះហោង, ជាគម្រប់បីដងផង ។

កាលវេរមតក ភត្តហើយ ត្រូវនិមន្តព្រះសង្ឃបង្សុកូល, លុះបង្សុកូលចប់ហើយ ត្រូវប្រគេនចង្ហាន់ នឹងទេយ្យទាន (១) ដល់ព្រះសង្ឃ ព្រះសង្ឃទទួលទេយ្យទានហើយ លោកសូត្រភត្តានុមោទនាតាមទម្លាប់ដែលធ្លាប់សូត្រមក ។ លោកសូត្រអនុមោទនាចប់ហើយ ឧបាសកសូត្រយំកិញ្ចិឧទ្ទិសផលជាកិច្ចបង្ហើយបុណ្យ។

*ចប់ពិធីបុណ្យមតកភត្តត្រឹមប៉ុណ្ណោះ ។*

---

(១) ពាក្យប្រែក្រក់ក្រចកត្រូវផ្លាស់តាមឈ្មោះភត្តដែលត្រូវការធ្វើ ។

(១) ចំណែកខាងបច្ច័យកប្បិយវារណាតាមពាក្យបវារណាក្នុងពិធីចម្រើនព្រះបរិត្តឯណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


## ៥. ពិធីបុណ្យសលាកភត្ត

ចង្ហាន់ដែលទាយកត្រូវធ្វើដោយពិធីចាប់ស្លាក ហៅថា «សលាកភត្ត» ។ បុណ្យនេះ សម័យបច្ចុប្បន្ន ទាយកតែងធ្វើរៀងរាល់ឆ្នាំ នៅខែពិសាខ-ជេស្ឋ- ឬអាសាធ ដែលជារដូវសម្បូរណ៍ផ្លែឈើផ្សេងៗ ។ សម័យពុទ្ធកាល ទាយកធ្វើដោយឥតកំណត់កាល ស្រេចតែមានសទ្ធាកាលណា គេនាំគ្នាធ្វើកាលនោះ

### អង្គនៃសលាកភត្ត

សលាកភត្ត មានអង្គ ២ គឺ

១. ការចាប់ស្លាកចំពោះលោកដែលសង្ឃចាត់មក

២. ទោះបានភិក្ខុចាស់ក្តី ក្មេងក្តី មិនសោមនស្ស មិនទោមនស្ស ។

លុះតែប្រកបដោយអង្គ ២នេះ ទើបបានផលបរិបូរណ៍ ។

### កាតព្វកិច្ចនៃសលាកភត្ត

ពិធីបុណ្យសលាកភត្ត ទាយកត្រូវរៀបចំធ្វើដោយកិច្ចចាត់ជា ៦ថ្នាក់គឺ

១. កិច្ចផ្សាយដំណឹងសលាកភត្ត

២. កិច្ចចាត់ចែងភត្តាហារ នឹងទេយ្យទាន

៣. កិច្ចចាប់ស្លាក

៤. កិច្ចនមស្សការព្រះរតនត្រ័យ នឹងសមាទានសីល

៥. កិច្ចវេរសលាកភត្ត

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



៦. កិច្ចឧទ្ទិសផល

កិច្ចទាំង ៦ថ្នាក់នេះ មានបរិយាយដូចតទៅ :

## ថ្នាក់ទី ១ កិច្ចផ្សាយដំណឹងបុណ្យសលាកភត្ត

បុណ្យសលាកភត្ត គេតែងធ្វើរួមគ្នា កាលបើគេបម្រុងនឹងធ្វើពេលណា មុននឹងធ្វើ គេតែងប្រកាសផ្សាយដំណឹងបុណ្យនេះ ផ្ទាល់មាត់ខ្លះ ធ្វើកម្មវិធីជូនដំណឹងខ្លះ ដោយប្រាប់កំណត់ថ្ងៃខែ- ពេលវេលា នឹងទីកន្លែងដែលត្រូវធ្វើ គឺវត្តអារាម ឬធម្មសាលាដែលមានក្នុងលង្វែកភូមិជាដើម ។ ឯកម្មវិធីជូនដំណឹងនោះ មានសេចក្ដីដូចខាងក្រោមនេះ ÷

## ដំណឹងបុណ្យសលាកភត្តំ

សូមជូនដំណឹងដល់ពុទ្ធបរិស័ទទាំងឡាយ សូមជ្រាប ។

ដោយពេលដែលត្រូវធ្វើសលាកភត្តមកដល់ហើយ ខ្ញុំសូមជូនដំណឹងថា : សលាកភត្តរបស់យើងក្នុងពេលនេះ ត្រូវធ្វើនៅថ្ងៃ......ខែ..... ឆ្នាំ........វេលា........ម៉ោង......... ព្រឹក .......នៅទី.........(១) ។

ដូច្នេះ បើលោកអ្នកមានសទ្ធាត្រូវការធ្វើ សូមអញ្ជើញយកទេយ្យទានទៅជួបជុំ នៅទីវត្ត..........តាមថ្ងៃនឹងម៉ោងដែលមានកំណត់ខាងលើនេះ ។

ឯទេយ្យទាននៃសលាកភត្តនោះ ត្រូវមានបាយ១ ឆ្នាំងសម្ល ១ឆ្នាំង -

(១) ត្រូវដាក់ថ្ងៃ ខែ ឆ្នាំដែលធ្វើ នឹងទីកន្លែងដែលធ្វើ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បង្អែម ១ចាន នឹងផ្លែឈើផ្សេងៗ តាមត្រូវការ ។ ទេយ្យទានក្រៅពីនេះ តាមសទ្ធា ។

*អាចារ្យសម្រាប់វត្ត*

## ថ្នាក់ទី ២ កិច្ចចាត់ចែងភត្តាហារនឹងទេយ្យទាន

កាលដល់ថ្ងៃដែលបានកំណត់ទុកក្នុង សេចក្ដីជូនដំណឹងបុណ្យនោះហើយ ទាយកអ្នកទទួលធ្វើសលាកភត្ត ត្រូវចាត់ចែងភត្តាហារ នឹងទេយ្យទានច្រើន ឬតិចតាមដែលជូនដំណឹងនឹងតាមសមត្ថភាពនាំទៅដំកល់ទុកនៅក្នុងសេចក្ដីជូនដំណឹងនោះ ។

## ថ្នាក់ទី ៣ កិច្ចចាប់ស្លាក

លុះយកទេយ្យទានទៅដំកល់ទុក នៅទីដែលបានកំណត់ទុកហើយ ត្រូវនាំគ្នាចាប់ស្លាក ។ ការចាប់ស្លាកមាន ២ បែប គឺ

ក) សរសេរនាមព្រះសង្ឃគ្រប់អង្គក្នុងវត្តដែលត្រូវទទួលសលាកភត្តនោះ ឬសរសេរត្រឹមចំនួនប៉ុន្មានអង្គដែលសង្ឃចាត់មកតាមកំណត់ លើក្រដាសសដែលកាត់ជាចម្រៀកតូចៗល្មមធ្វើជារម្មូរយកទៅដាក់ក្នុងភាជន៍១សម្រាប់អោយទាយកចាប់, ឱ្យកាលទាយកចាប់បាននាមព្រះសង្ឃអង្គណាត្រូវប្រគេនដល់ព្រះសង្ឃអង្គនោះ ។

ខ) សរសេរលេខតាំងពី ១ ទៅត្រឹមចំនួនព្រះសង្ឃគ្រប់អង្គក្នុងវត្ត ឬតែត្រឹមចំនួនប៉ុន្មានអង្គដែលសង្ឃចាត់មកតាមកំណត់ ធ្វើជារម្មូរអោយទាយកម្ចាស់ទានយកទៅសៀតទុកនៅទេយ្យទានរបស់ខ្លួនរៀងខ្លួន ហើយ-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


សរសេរលេខតាំងពី ១ ទៅ របៀបដូចគ្នានេះអោយព្រះសង្ឃចាប់ បើភិក្ខុណាចាប់បានលេខប៉ុន្មាន ត្រូវនឹងលេខរបស់ទាយកណាទាយកនោះត្រូវប្រគេនទេយ្យទានដល់ភិក្ខុនោះ ។

## ថ្នាក់ទី ៤ កិច្ចនមស្សការព្រះរតនត្រ័យ នឹងសមាទានសីល

កាលបើគណៈកម្មការបុណ្យ បានចាត់ចែងការចាប់ស្លាកបែបណា ទាយកទាយិកា បានចាប់តាមបែបនោះហើយ ទាយកទាយិកាត្រូវនាំគ្នានមស្សការព្រះរតនត្រ័យ នឹងសមាទាននិច្ចសីលឬឧបោសថសីល តាមកាលវេលា ដែលធ្វើសលាកភត្តនោះគឺបើធ្វើក្រៅពីថ្ងៃសីល ត្រូវសមាទាននិច្ចសីល បើធ្វើក្នុងថ្ងៃសីលត្រូវសមាទានឧបោសថសីល (១) ។

## ថ្នាក់ទី ៥ កិច្ចវេរសលាកភត្តៈ

បន្ទាប់ពីនមស្សការ នឹងសមាទានសីល ទាយកជាប្រធានឬអាចារ្យនាំសូត្រវេរសលាកភត្ត ដូចតទៅនេះ :

នមោ តស្ស ។ល។ សម្មាសម្ពុទ្ធស្ស ។ ៣ ដង ។

រួចហើយ សូត្រវេរ ៣ លើក :

លើកទី ១ ថា :

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ

(១) នមស្សការព្រះរតនត្រ័យ នឹងសមាទានសីល សូមយកតាមពាក្យនមស្សការ នឹងសមាទានសីល ក្នុងពិធីចម្រើនព្រះបរិត្តនៅទំព័រខាងដើម ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (សលាកភត្តំ (១)) សបរិក្ខា សង្ឃស្ស ទេម តេ គុណវន្តានយោ ឥមំ (សលាកភត្តំ) អត្តនោសន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។

លើកទី ២ ថា :

ទុតិយម្បិ អយំ នោ ភន្តេ ។ ល ។ និស្សន្ទេន ។

លើកទី ៣ ថា :

តតិយម្បិ អយំ នោ ភន្តេ ។ ល ។ និស្សន្ទេន ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយវេរ (នូវសលាកភត្ត) នេះព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃ, សូមលោកអ្នកមានគុណទាំងឡាយមានមាតា នឹងបិតាជាដើមនោះ សំគាល់នូវ (សលាកភត្ត) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ, លុះអនុមោទនារួចហើយសូមឱ្យរួចរំដោះចាកទុក្ខទាំងពួង អោយបានសម្រេចដោយសម្បត្តិទាំង ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា១-

---

(១) បាលីវេរនេះ ស្រង់ពីសៀវភៅគិហិបដិបត្តិ ដែលមានចែងថា បាលីនេះប្រើបានគ្រប់ភត្តទាំង ១៤ គឺបើទាយកត្រូវការធ្វើតត្តណា គប្បីដាក់ឈ្មោះភត្តនោះគ្រប់កន្លែងវង់ក្រចកនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហួរជូនមកមិនដាច់នេះហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ នេះហោង, ជាគម្រប់ ពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ ល ។ នេះហោង, ជាគម្រប់បីដងផង ។

វេររួចហើយ គប្បីប្រគេនសលាកភត្ត ព្រមទាំងទេយ្យទាន (១) ដោយគោរព ។

## ថ្នាក់ទី ៦ កិច្ចឧទ្ទិសផល

វេរចប់ហើយ បដិគ្គាហក លោកសូត្រភត្តានុមោទនា។ ចប់ហើយ ទាយកទាយិកាត្រូវនាំគ្នាសូត្រឧទ្ទិសផល (២) ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យសលាកភត្តត្រឹមប៉ុណ្ណេះ ។

(១) ចំណែកខាងបច្ច័យ គប្បីបវារណាតាមពាក្យបវារណាដែលមានក្នុងពិធីចម្រើនព្រះបរិត្តឯណោះ។

(២) ពាក្យឧទ្ទិសផលសូមយកតាមក្នុងពិធីចម្រើនព្រះបរិត្តនៅទំព័រខាងដើម នៃសៀវភៅនេះ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


## ៦. ពិធីបុណ្យភេសជ្ជទាន

ការកុសលដែលធ្វើដោយវេរថ្នាំកែរោគ ប្រគេនព្រះសង្ឃហៅថា «បុណ្យភេសជ្ជទាន» ។

ក្នុងវិនយបិដក មហាវគ្គ ត្រង់ភេសជ្ជក្ខន្ធកៈ ចែងថាកាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន ទ្រង់ជ្រាបថា ពួកភិក្ខុមានអាពាធគ្រុនស្រៀវស្រាញ់ក្នុងសរទកាល ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទួលភេសជ្ជៈ ៥យ៉ាង គឺទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ, ទឹកអំពៅ, របស់ទាំងអស់នេះ ជាភេសជ្ជៈផង គេសន្មត់ថាជាភេសជ្ជៈ ជាអាហាររបស់មនុស្សលោកផង ឱ្យភិក្ខុទទួលភេសជ្ជៈទាំង ៥ នេះ ក្នុងកាលគួរ បរិភោគក្នុងកាលគួរ (តាំងពីពេលអរុណរះទៅទាល់ពីថ្ងៃត្រង់ក៏បាន ក្នុងកាលមិនគួរតាំងពីពេលថ្ងៃជ្រេរពីត្រង់ទៅទល់អរុណរះ) ក៏បាន ។

លំដាប់តៗ មក ទ្រង់អនុញ្ញាតិវត្ថុជាភេសជ្ជៈ ច្រើនប្រការជាអាទិគឺ :

- ពួកខ្លាញ់ មានខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ជាដើម ។
- ពួកឫស មើម មានមើមរមៀត មើមខ្ញីជាដើម ។
- ពួកទឹកចត់ មានទឹកចត់កើតពីដើមស្ដៅជាដើម ។
- ពួកស្លឹក មានស្លឹកស្ដៅជាដើម ។
- ពួកផ្លែ មានផ្លែជីផ្លី ម្រេច ជាដើម ។
- ពួកជ័រ មានជ័រហិង្គុ ជាដើម ។

.........................

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



ឯល្វា ការី ទឹកតែ កាហ្វេ ទឹកកក ទឹកក្រូច ទឹកម្ទូំណាត់ ស្ករស ស្ករត្នោត ស្ករក្រាម ស្ករតាំងស៊ិន លោកសង្គ្រោះចូលជា ភេសជ្ជៈដែលទ្រង់អនុញ្ញាតដែរ ហៅថាអនុលោមភេសជ្ជៈ ។

បើទាយកត្រូវការធ្វើភេសជ្ជៈ ដូចពោលហើយនោះ ប្រគេនព្រះសង្ឃ ហៅថា ភេសជ្ជទាន ។

ពិធីបុណ្យភេសជ្ជៈទានមិនមានបែបបទច្រើនទេ, បើទាយកចូលចិត្តធ្វើភេសជ្ជបែបណា ហើយបានចាត់ចែងធ្វើបែបនោះចង់យកទៅប្រគេនព្រះសង្ឃឯវត្តក៏បាន ចង់និមន្តព្រះសង្ឃមកប្រគេនឯផ្ទះក៏បាន, បើត្រូវការទៅធ្វើឯវត្តត្រូវនាំភេសជ្ជៈទៅរៀបវេរប្រគេនព្រះសង្ឃឯវត្ត បើត្រូវការធ្វើឯផ្ទះត្រូវរៀបចំទីសេនាសនៈ នឹងគ្រឿងដាក់ភេសជ្ជៈមានកែវជាដើមឯផ្ទះ ហើយនិមន្តព្រះសង្ឃពីវត្តមកវេរប្រគេនឯផ្ទះ, កាលណាព្រះសង្ឃនិមន្តមកដល់ផ្ទះ ត្រូវទទួលបដិសណ្ឋារៈលោកដោយប្រពៃហើយ ត្រូវនាំគ្នាវេរភេសជ្ជទាននោះ ចំពោះព្រះសង្ឃតាមមុខភេសជ្ជៈដែលខ្លួនត្រូវធ្វើ គឺបើធ្វើទឹកអំពៅត្រូវចេញឈ្មោះទឹកអំពៅ បើធ្វើទឹកឃ្មុំ ត្រូវវេរចេញឈ្មោះទឹកឃ្មុំដូចតទៅនេះ ÷

មុនដំបូង អ្នកនាំសូត្រត្រូវនាំតាំងនមោ ៣ ដងហើយនាំសូត្រវេរ ៣ លើក ដូចខាងក្រោម :

លើកទី ១ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer

មយំ ភន្តេ ឥមំ (មធុំ)(១) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម ភិក្ខុសង្ឃោ ឥមំ (មធុំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ល។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបាននាំមក (នូវទឹកឃ្មុំ) នេះ តំកល់ទុកក្នុងទីនេះ សូមវេរប្រគេន ចំពោះព្រះភិក្ខុសង្ឃ បពិត្រព្រះតម្លែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយក (នូវទឹកឃ្មុំ) នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើង។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង, ជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង, ជាគម្រប់បីដងផង កាលឧបាសក

---

(១) បើវេរប្រេងត្រូវថា តេលំ នូវប្រេង ។ បើវេរទឹកអំពៅ ត្រូវថា ផាណិតំ នូវទឹកអំពៅ ។ បើវេរទឹកត្នោត ត្រូវថា តាលោទកំ នូវទឹកត្នោត ។ បើវេរថ្នាំរម្ងាប់រោគ ត្រូវថាគិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្សឈឺ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


វេរចប់ហើយ ព្រះសង្ឃសូត្រអនុមោទនាចប់ធម៌អនុមោទនា ឧបាសកសូត្រ យំកិញ្ចិ ឧទ្ទិសផល (១) ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យភេសជ្ជៈទានត្រឹមប៉ុណ្ណេះ ។

## ៧. ពិធីបុណ្យកឋិន

ការកុសលដែលធ្វើ ដោយនាំសំពត់ចីវរទៅប្រគេនព្រះសង្ឃដែលបានគង់ចាំវស្សាអស់ត្រៃមាស ក្នុងអាវាសណាមួយ ក្នុងវេលា ២៩ថ្ងៃ គឺតាំងពី ១រោច ខែអស្សុជ ទៅទល់នឹង ១៥កើត ខែកត្តិក ឱ្យលោកក្រាលគ្រង ដើម្បីលោកបានអានិសង្ស ៥តាមពុទ្ធអនុញ្ញាត ហៅថា បុណ្យកឋិន ឬកឋិនទាន ។

កឋិនទាន ជាទានពិសេស ប្លែកពីទានទាំងពួង ដោយហេតុ ៥យ៉ាង គឺ :

១. ប្លែកដោយកាល គឺបុណ្យនេះ មិនអាចធ្វើរាល់ថ្ងៃរាល់ខែបានទេ ដោយមានពុទ្ធានុញ្ញាត ជាពិសេសថាក្នុង ១ឆ្នាំធ្វើតែរវាង ២៩ថ្ងៃ គឺតាំងពីថ្ងៃ ១ រោច ខែ អស្សុជ ទៅទល់នឹងថ្ងៃពេញបូណ៌មី ខែកត្តិកប៉ុណ្ណោះ, ក្នុងរយៈកាល ២៩ ថ្ងៃនេះធ្វើក្នុងថ្ងៃណាមួយក៏បាន ហើយ ១វត្តធ្វើបានតែម្តងក្នុង ១ រដូវ ។

២. ប្លែកដោយវត្ថុ គឺសំពត់ដែលជាកឋិនវត្ថុ បានតែស្បង់ ឬចីពរ ឬ

---

(១) ពាក្យយំកិញ្ចិ មានទាំងបាលីទាំងសេចក្តីប្រែ ក្នុងពិធីចំរើនព្រះបរិត្តឯណោះហើយ សូមយកតាមនោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ក៏សង្ឃាដី ដែលត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិប៉ុណ្ណោះ ក្រៅពីនេះពុំបាន សូម្បីវត្ថុទាំង ៣នេះ នឹងធ្វើទាំង ៣មុខ ជាអង្គកឋិន ១ ក៏ពុំបាន បានតែមួយមុខក្នុងកឋិន១, ទោះបីទាយកគេវេរចីវរ១ ត្រៃជាសំពត់កឋិន ក៏លោកអ្នកក្រាលគ្រង លោកបើសយកតែវត្ថុណាមួយធ្វើជាអង្គកឋិន គឺស្រេចតែលើព្រះទ័យលោក លោកចង់យកស្បង់ជាអង្គកឋិនក៏បានចីពរក៏បាន សង្ឃាដីក៏បាន ឱ្យតែវត្ថុនោះ ៗត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ។

៣. ប្លែកដោយអំពើ គឺបុគ្គលអ្នកធ្វើ គប្បីធ្វើឱ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ហើយសង្ឃក៏គប្បីក្រាលគ្រងឱ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិដែរ ទើបកើតជាកឋិនត្រឹមត្រូវបានអានិសង្ស ។

៤. ប្លែកដោយអានិសង្ស គឺបុគ្គលអ្នកធ្វើក៏បានអានិសង្ស ៥យ៉ាង (១)ដូចមានចែងក្នុងវិនយបិដក ភាគ ៩ ត្រង់កឋិនក្ខន្ធកៈនោះសព្វគ្រប់ស្រាប់ ។

៥. ប្លែកដោយបដិគ្គាហកៈ (អ្នកទទួល) គឺបានតែភិក្ខុ ក្រៅពីនេះពុំបាន, ហើយភិក្ខុទៀត លុះតែបាននៅចាំវស្សាអស់ ៣ខែ ទើបបាន ។

វិនយបិដកកឋិនក្ខន្ធកៈនោះ មានចែងពីប្រភពនៃកឋិនថា :

ក្នុងបឋមពោធិកាល ដែលព្រះបរមសាសាទ្រង់ឱ្យភិក្ខុប្រើប្រាស់តែបង្សុកូលចីវរ ពុំទាន់ឱ្យប្រើគហបតីចីវរនៅឡើយ, សម័យមួយ កាលដែលទ្រង់គង់ចាំព្រះវស្សានៅវត្តជេតពន ជិតដល់ថ្ងៃចូលវស្សាភិក្ខុ ៣០អង្គ នៅ

---

(១) បើចង់ជ្រាបរឿងអានិសង្ស ៥សូមមើលក្នុងវិនយបិដក ភាគ៩ ត្រង់កឋិនក្ខន្ធកៈនោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ស្រុកបាវាប្រាថ្នាចង់មកថ្វាយបង្គំព្រះអង្គមុនថ្ងៃចូលវស្សា តែមកមិនទាន់ ក៏ចូលវស្សានៅជនបទមួយត្រង់កណ្តាលផ្លូវ ។ ដល់បវារណាចេញវស្សាហើយ ទើបនាំគ្នាមកថ្វាយបង្គំព្រះអង្គ ។ ដោយពេលដែលភិក្ខុមកនោះភ្លៀងច្រើនពេក ភិក្ខុទាំងនោះ មានស្បង់ចីពរទទឹកជោកដោយទឹកភ្លៀង ហើយដោយហេតុតែចង់ឃើញព្រះភក្ត្រព្រះអង្គឆាប់ៗ ក៏នាំគ្នាចូលទៅថ្វាយបង្គំទាំងស្បង់ចីពរទទឹកនោះ ។ ព្រះអង្គទតឃើញដូច្នោះ ក៏ទ្រង់អនុញ្ញាតឱ្យភិក្ខុក្នុងព្រះពុទ្ធសាសនាទទួលសំពត់កឋិនដែលជាគហបតីចីវរបាន ហើយទ្រង់អនុញ្ញាតថា ភិក្ខុដែលបានទទួលក្រាលគ្រង បានទទួលអនុមោទនាកឋិននោះត្រូវបានទទួលអានិសង្ស ៥យ៉ាង ។ ភិក្ខុក្នុងព្រះពុទ្ធសាសនាក៏បានទទួលកឋិនចីវរ អំពីគហបតី តាំងពីពេលនោះមក ។

## កាតព្វកិច្ចនៃកឋិនទាន

កិច្ចបុណ្យកឋិនដែលខ្មែរយើងតែងធ្វើជាប់ជាប្រពៃណីតាំងពីបុរាណកាលមក មាន ៨ថ្នាក់ គឺ÷

១. កិច្ចធ្វើសំពត់កឋិន

២. កិច្ចសុំវត្តធ្វើកឋិន

៣. កិច្ចផ្សាយដំណឹងបុណ្យកឋិន

៤. កិច្ចសូត្រមន្តកឋិននឹងទេសនា

៥. កិច្ចហែកឋិន

៦. កិច្ចសូត្រសុន្ទរកថាពណ៌នាពីបុណ្យកឋិន

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៧. កិច្ចវេរសំពត់កឋិនដឹងបរិក្ខារជាបរិវារកឋិន

៨. កិច្ចឧទ្ទិសផល

### ថ្នាក់ទី ១ កិច្ចធ្វើសំពត់កឋិន

តាមពុទ្ធានុញ្ញាត សំពត់ដែលជាវត្ថុនៃកឋិននោះទោះជាសំពត់ថ្មីក៏បាន សំពត់ចាស់ដែលបោកស្អាតក៏បាន សំពត់បង្សុកូលក៏បាន សំពត់ធ្លាក់ក្នុងកន្លោះរានផ្សារក៏បាន ដែលអ្នកណានីមួយជាគ្រហស្ថក៏ដោយ ជាសហធម្មិក (១) ក៏ដោយ បានវេរប្រគេនសង្ឃហើយ សុទ្ធតែជាសំពត់គួរក្រាលកឋិនបានទាំងអស់ ។

មួយយ៉ាងទៀត សំពត់ដែលមានបរិកម្មស្រេចហើយ គឺសំពត់ដែលទាយកបានកាត់ដេរជាស្បង់ជាចីពរជាសង្ឃាដី ជ្រលក់ពណ៌ត្រឹមត្រូវស្រេចហើយ យកមកវេរចំពោះសង្ឃ ដើម្បីឱ្យសង្ឃក្រាលគ្រងស្រេចតែម្តង នោះសង្ឃអាចក្រាលគ្រងបានមិនបាច់រុះរើកាត់ដេរជ្រលក់ទៀតទេដូចយ៉ាងកុលបុត្រដែលមានសទ្ធាជ្រះថ្លា បើស្បង់ចីពរចូលមកសួរបុព្វជា ទាំងសក់មិនទាន់កោរ នោះឧបជ្ឈាយ៍ត្រូវតែកោរសក់ចេញ ទើបបំបួសបាន បើគេកោរសក់រួចស្រេចហើយ ឧបជ្ឈាយ៍ត្រូវតែបំបួសឱ្យតែម្តងមិនចាំបាច់កោរសក់ឱ្យទៀតទេ, ឯសំពត់កឋិនក៏ដូច្នោះដែរ បើទាយកគេធ្វើត្រឹមត្រូវស្រេចហើយសង្ឃស្រាប់តែទទួលក្រាលគ្រងតែម្តងបាន គ្មានកិច្ចត្រូវធ្វើទៀតឡើយ ។

អាស្រ័យដោយមានពុទ្ធានុញ្ញាតដូច្នេះ បានជាសម័យបច្ចុប្បន្ននេះ

---

(១) អ្នកប្រព្រឹត្តធម៌ជាមួយគ្នាមាន ៥គឺភិក្ខុ ភិក្ខុនី សាមណេរៈ សាមណេរី សិក្ខមានា ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៧. កិច្ចវេរសំពត់កឋិននឹងបរិក្ខារជាបរិវារកឋិន

៨. កិច្ចឧទ្ទិសផល

## ថ្នាក់ទី ១ កិច្ចធ្វើសំពត់កឋិន

តាមពុទ្ធានុញ្ញាត សំពត់ដែលជាវត្ថុនៃកឋិននោះទោះជាសំពត់ថ្មីក៏បាន សំពត់ចាស់ដែលបោកស្អាតក៏បាន សំពត់បង្សុកូលក៏បាន សំពត់ធ្លាក់ក្នុងចន្លោះរានផ្សារក៏បាន ដែលអ្នកណានីមួយជាគ្រហស្ថក៏ដោយ ជាសហធម្មិក (១) ក៏ដោយ បានវេរប្រគេនសង្ឃហើយ សុទ្ធតែជាសំពត់គួរក្រាលកឋិនបានទាំងអស់ ។

មួយយ៉ាងទៀត សំពត់ដែលមានបរិកម្មស្រេចហើយ គឺសំពត់ដែលទាយកបានកាត់ដេរជាស្បង់ជាចីពរជាសង្ឃាដី ជ្រលក់ពណ៌ត្រឹមត្រូវស្រេចហើយ យកមកវេរចំពោះសង្ឃ ដើម្បីឱ្យសង្ឃក្រាលគ្រង់ស្រេចតែម្តង នោះសង្ឃអាចក្រាលគ្រងបានមិនបាច់រុះរើកាត់ដេរជ្រលក់ទៀតទេដូចយ៉ាងកុលបុត្រដែលមានសទ្ធាជ្រះថ្លា បីស្បង់ចីពរចូលមកសួរបុព្វជា ទាំងសក់មិនទាន់កោរ នោះឧបជ្ឈាយ៍ត្រូវតែកោរសក់ចេញ ទើបបំបួសបាន បើគេកោរសក់រួចស្រេចហើយ ឧបជ្ឈាយ៍ត្រូវតែបំបួសឱ្យតែម្តងមិនចាំបាច់កោរសក់ឱ្យទៀតទេ, ឯសំពត់កឋិនក៏ដូច្នោះដែរ បើទាយកគេធ្វើត្រឹមត្រូវស្រេចហើយសង្ឃស្រាប់តែទទួលក្រាលគ្រងតែម្តងបាន គ្មានកិច្ចត្រូវធ្វើទៀតឡើយ ។

អាស្រ័យដោយមានពុទ្ធានុញ្ញាតដូច្នេះ បានជាសម័យបច្ចុប្បន្ននេះ

---

(១) អ្នកប្រព្រឹត្តធម៌ជាមួយគ្នាមាន ៥គឺភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី សិក្ខមានា ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


# ដំណឹងបុណ្យកឋិន

យើងខ្ញុំមានមានដូចខាងក្រោម បានចាត់ចែងធ្វើកឋិនទាននឹងដង្ហែរទៅវេរ ប្រគេនចំពោះព្រះសង្ឃដែលគង់ចាំវស្សា នៅវត្ត. . . . . ឃុំ. . . ស្រុក. . . . . ខែត្រ(១) ។

សូមអស់លោក អ្នកសប្បុរសទទួលអនុមោទនា នឹងជួយឧបត្ថម្ភការបុណ្យនេះ តាមកាលបរិច្ឆេទដូចខាងក្រោម ÷

## កម្មវិធីបុណ្យ

ថ្ងៃ. . . . . . ខែ. . . . . . . ឆ្នាំ. . . . វេលាម៉ោង (២) ជួបជុំគ្នានិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត ទេសនា នៅក្នុងវត្ត ឬក្នុងផ្ទះ. . . . ឃុំ. . . . ស្រុក. . . . ខែត្រ. . . .(៣) . . . ។

ព្រឹកឡើងថ្ងៃទី. . . ខែឆ្នាំដដែល វេលាម៉ោង. . . . ដង្ហែរទៅប្រគេនព្រះសង្ឃ នៅវត្តដូចខាងលើ ។

## នាមអ្នកផ្តើមបុណ្យ

. . . . . . . . . . . . . . . . . . . . . . . . . . . . . .(១) ។

---

[illegible] ដាក់ពេលវេលាវត្តដែលត្រូវកឋិន

(២) ត្រូវ[illegible] ថ្ងៃខែឆ្នាំ និងពេលដែលធ្វើ ។

(៣) បើវត្តត្រូវដាក់ឈ្មោះវត្ត បើផ្ទះត្រូវដាក់ឈ្មោះម្ចាស់ផ្ទះ ។

(១) ត្រូវដាក់ឈ្មោះអ្នកផ្តើមធ្វើ បើគ្នាច្រើនតាមច្រើន គ្នាតិចតាមតិច ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



## ថ្នាក់ទី ៤ កិច្ចសូត្រមន្តកឋិន

កាលដល់ថ្ងៃសូត្រមន្ត, បើគេត្រូវការសូត្រនៅវត្ត គេក៏រៀបចំនៅវត្ត បើគេត្រូវការសូត្រនៅផ្ទះ គេក៏រៀបចំនៅផ្ទះ ។ ឯរបៀបរៀបចំនោះ គេរៀបចំទេយ្យទាន ២ ចំណែក គឺ :

១. សម្រាប់លោកអ្នកក្រាលគ្រងកឋិន ១ អង្គ ១ ចំណែក ។

២. សម្រាប់លោកអ្នកសូត្រញត្តិកឋិន ២ អង្គ ២ ចំណែក ។

ចំណែកទី ១ រៀបចីវរ ១ ត្រៃ ព្រមទាំងអង្សកវត្តពន្ធដឹកលលើតុ ឬតោក ១ ដោយមានរនាបឫស្សី ឬបន្ទះក្តារជាជើងទ្រដាក់តងពីលើមាត់តុឬតោកនោះ ហើយមានបន្ទះក្តារស្រែះកង្កាំស្រោបពីលើ ជាអង្គកឋិនសម្រាប់លោកអ្នកក្រាលគ្រង ១ អង្គ ។

ចំណែកទី ២ រៀបតុឬតោក ២ទៀត មួយដឹកលចីវរ ១ លៀងគឺស្បង់ចីពរ ១ ដោយមានរនាបឫស្សី ឬបន្ទះក្តារជាជើងទ្រ នឹងមានបន្ទះក្តារស្រែះកង្កាំស្រោបពីលើដូចគ្នា រៀបដាក់បន្ទាប់ពីតុត្រៃអង្គកឋិននោះ សម្រាប់លោកសូត្រញត្តិ ២ អង្គ ។

ហើយមានរៀបគ្រឿងបរិក្ខារ ជាបរិវារកឋិនទៀត ។

គ្រឿងបរិក្ខារនោះ គេរៀបជា ៤ចំណែក :

១. សម្រាប់លោកអ្នកក្រាលគ្រង ១ ចំណែក

២. សម្រាប់លោកអ្នកសូត្រញត្តិ ២ អង្គ ២ ចំណែក

៣. សម្រាប់លោកអ្នកគង់ហត្ថបាសតាមចំនួន

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៤. សម្រាប់លោកសាមណេរតាមចំនួន

ទាំង ៤ ចំណែកនេះ មានរបៀបខុសគ្នាតាមថ្នាក់ គឺ÷

ចំណែកទី ១ សម្រាប់លោកអ្នកក្រាលគ្រង ១អង្គ មានបាត្រ ធំត្រ ផ្តិល កំសៀវទឹក ចានស្រាក់ ចានថ្ម ស្លាបព្រា កន្សែងដៃ មុង កន្ទេល ខ្នើយ គ្រែសណឹង គ្រែទេសន៍ សម័យបុរាណគេមិនខានធ្វើក្រាំងឬវានបាតិមោក្ខទេ សម័យបច្ចុប្បន្នគេដាក់សៀវភៅធម៌វិន័យផ្សេងៗ សៀវភៅសរសេរ ទឹកខ្មៅ ខ្មៅដៃ ស្លាបប៉ាកការ ដងប៉ាកកា ។ល។

ចំណែកទី ២ សម្រាប់លោកអ្នកសូត្រញត្តិ ២អង្គ មានកន្ទេលខ្នើយ ធំត្រ ស្បែកជើង ។ល។

ចំណែកទី ៣ សម្រាប់លោកភិក្ខុបរិស័ទដែលគង់ហត្ថបាសមាន ស្បង់ ១ នឹងបរិក្ខាររាយរង ១ ប្រដាប់ ១អង្គ តាមចំនួនដែលមានក្នុងវត្ត នោះ ។

ចំណែកទី ៤ សម្រាប់លោកសាមណេរ មានសំពត់សាដក ១ នឹង បរិក្ខាររាយរង ១ ប្រដាប់ ១ អង្គ តាមចំនួនដែលមានក្នុងវត្តនោះ ។

ប្រដាប់ទាំង ៤ ចំណែកនោះ គេរៀបខ្ចប់ជាកញ្ចប់ៗ ដោយក្រដាស់ ថ្លារលោងមើលឃើញអីវ៉ាន់ខាងក្នុងគួរអោយជ្រះថ្លា រៀបរួចហើយ ដល់ ពេលម៉ោង ៧យប់ គេជួបជុំគ្នាថ្វាយបង្គំព្រះ សមាទានសីល និមន្តព្រះសង្ឃ ចម្រើនព្រះបរិត្ត (១) រួចអារាធនាព្រះធម្មកថិកសំដែងធម៌ទេសនា តាមគួរ

(១) ពាក្យថ្វាយបង្គំព្រះ សមាទានសីល នឹងអារាធនាព្រះបរិត្តមានសព្វគ្រប់ក្នុងពិធីចម្រើន ព្រះបរិត្តឯណោះហើយ សូមយកតាមនោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ដល់កាលវេលា ។

### ពាក្យអារាធនាធម៌ទេសនា

ព្រហ្មា ច លោកាធិបតី សហម្បតិ
កតញ្ជលី អន្ធិវរំ អយាចថ
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
សម្ពុតេរី ចិនយញ្ញ កាយិ
សុត្តញ្ញ ពន្ធំ អភិធម្មចម្មំ
អាកោដយន្តោ ចតុស្សច្ចនណ្ឌំ
បញ្ចោធ នេយ្យោ បរិសាយ មជ្ឈេ ។

### ប្រែពាក្យអារាធនាធម៌

បទព្រហ្មគីតិ

| | |
|---|---|
| គ្រានោះសហម្បតី | ព្រហ្មជាឥស្សរលោកា |
| ចូលគាល់ព្រះសាស្តា | លើកហត្ថាសិរោរាប ។ |
| ហើយពោលពាក្យទូលថា | សូមករុណាស្តេចទ្រង់ជ្រាប |
| ដ្បិតសត្វអន់ទន់ទាប | ទុព្វលភាពបាបក្រៃក្រាស់ ។ |
| ទន្ទឹងព្រះធម៌ថ្លៃ | ជានិស្ស័យបច្ច័យច្បាស់ |
| ឥឡូវទ្រង់បានត្រាស់ | ត្រេកអរណាស់ពុំកន្តើយ ។ |
| សត្វខ្លះក្រាស់ដោយកាម | មិនយល់តាមត្រៃលក្ខណ៍ឡើយ |

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ឥឡូវយល់ខ្លះហើយ　　ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា　　បញ្ញាភ្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ　　ទ្រង់និមន្ដត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក　　ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា　　កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃល័ក្ខណ៍　　សង្សារចក្រវិលមិនដល់
អវិជ្ជាជាឫសគល់　　ជាបច្ច័យនៃសង្ខារ ។
នាំសត្វអោយសោកសៅ　　លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ　　វិតរុំហ៊ុំជុំជាប់នៅ ។
ហេតុនោះសូមព្រះអង្គ　　ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្ពោះទៅ　　កាន់ត្រើយត្រាណនិព្វាននាយ ។
ដូចកល់ប្រទីបធំ　　សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ　　ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្គរជ័យ　　ព្រះវិន័យជាកងធំ
ព្រះសូត្រជាខ្សែរុំ　　ព្រះអភិធម្មជាស្បែកដាស ។
អរិយសច្ចជាអន្លង　　សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកងោកងុយណាស់　　ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ ៤ជំពូក　　ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះផុសចាំសុរ្យធាន　　រះនឹងរីកដោយរស្មី ។
ព្រះធមិជាសូរ្យសែង　　រះឡើងចែងចាំងរស្មី ។

www.budinst.gov.kh　　www.elibraryofcambodia.org

www.facebook.com/7khmer



បំភ្លឺលោកទាំងបី ឱ្យយល់ផ្លូវឋានសុខា ។
សហម្បតីព្រហ្ម និនបង្គំអារាធនា
សម្ដេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសំដែង ។
ដោយតុណ្ហីភាពថ្លៃ តាមភារៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គិយជាអាទិ
ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សំដែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរត្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពុទ្ធបរិស័ទ ដែលដាច់ខាតដោយមេហា
ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ។
កាលអាចារ្យអារាធនាធម៌ហើយ ព្រះធម្មកថិកលោក
សំដែងធម៌តាមគួរដល់ទាន នឹងកាលវេលា ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


លោកសំដែងធមិចប់ ឧបាសកសូត្រយិកិញ្ចិ ឧទ្ទិសផល់[១]

## ថ្នាក់ទី ៥ កិច្ចហែកឋិន

តាមទំនៀមការហែកឋិន គេតែងធ្វើគ្រែតូច ១ ហៅថាសង្សឹក ទំហំបណ្ដោយ ១ម៉ែត្រ ៥០ ទទឹង ១ ម៉ែត្រ មានជើង ៤ កំពស់ ៣០សង្ទីម៉ែត្រ សម្រាប់ដាក់គ្រឿងបរិក្ខារសែងហែ ។ លុះព្រឹកឡើង ពេលម៉ោង ៧ ឧបាសកជាញាតិមិត្តជិតឆ្ងាយ ព្រមទាំងព្រះសង្ឃ ដែលត្រូវតាមទៅហែ មកជួបជុំយ៉ាងកុះករ, បើវត្តដែលត្រូវហែកឋិនទៅនោះ នៅជិតផ្ទះអ្នកដើមការកឋិន គេហែដើរបើវត្តនោះ នៅឆ្ងាយ គេហែដោយរថយន្តតាមជើងគោកឬកប៉ាល់តាមជើងទឹក ដោយមានភ្លេងតូរ្យតន្ត្រីយ៉ាងគគ្រឹកគគ្រេងទៅផង ។

## ថ្នាក់ទី ៦ កិច្ចសូត្រសុន្ទរកថា

លុះហែទៅដល់វត្តដែលត្រូវការនោះហើយ អ្នកដើមការស្រ្តីទូលគ្រែអង្គកឋិន អ្នកដើមការប្រុសកាន់បាត្រ ឬ បរិក្ខារពួកញាតិមិត្ត ខ្លះកាន់បរិក្ខារផ្សេងៗ ខ្លះសែងសង្សឹកបរិក្ខារ ដើរហែប្រទក្សិណព្រះវិហារជាទក្ខិណាព័ដ៏ (វិលស្ដាំ) ៣ជុំ ហើយទូលគ្រែចូលទៅក្នុងព្រះវិហារ ដាក់គ្រែអង្គកឋិនចំពោះមុខព្រះសង្ឃក្នុងហត្ថបាស[១] ដាក់គ្រឿងបរិក្ខារផ្សេងៗ ក្នុងទីជិតៗនោះហើយ គេនាំគ្នាថ្វាយបង្គំព្រះ សមាទានសីល រួចអ្នកដើមការ-

---

(១) ពាក្យយិកិញ្ចិឧទ្ទិសផល មានក្នុងពិធីចម្រើនព្រះបរិត្តឯណោះហើយសូមយកតាមនោះចុះ

(១) តាមព្រះវិន័យថា ហត្ថបាសប្រគេនមានខ្នាត ២ ហត្ថ ១ ចំអាម គឺត្រូវគិតពីទីបំផុតខាងក្រោយនៃព្រះសង្ឃមកជា ១ ហត្ថ ពីទីបំផុតបង្អួយខាងមុខនៃឧបាសកទៅ ១ ហត្ថ ១ ចំអាម

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ឬអ្នកតំណាង ក្រោកឈរឡើងសូត្រសុន្ទរកថា ពណ៌នាពីដំណើរបុណ្យ មានសេចក្តីជាអាទិ ដូចទៅនេះ :

## សុន្ទរកថាបុណ្យកឋិន

បពិត្រព្រះករុណាគ្រប់ព្រះអង្គ អស់លោកអ្នកសប្បុរសទាំងឡាយ ខ្ញុំព្រះករុណា ខ្ញុំ (តាងនាមអ្នកដើមការបុណ្យ ) (១) សូមឱកាសពណ៌នាដោយសង្ខេប នូវបុព្វហេតុនៃបុណ្យកឋិននេះប្រគេន នឹងជូនជាដំណឹងដល់ព្រះករុណាគ្រប់អង្គនឹងអស់លោក- អ្នកសប្បុរសបានជ្រាបដូចតទៅនេះ :

បុណ្យកឋិននេះកើតឡើងដោយហេតុ ៤ យ៉ាង គឺ

១- ដោយហេតុយើងខ្ញុំបានស្តាប់ព្រះធម៌ព្រះវិន័យពុទ្ធសាសនា បានដឹងថាកឋិនទាន ជាកាលទានមានផលពិសេសជាងទានទាំងពួង ព្រោះបានផលដល់ទាយកជាម្ចាស់ទានផង បានអានិសង្សដល់ភិក្ខុជាបដិគ្គាហកៈអ្នកទទួលក្រាលគ្រង នឹងអ្នកអនុមោទនាផង ។

២- ដោយហេតុយើងខ្ញុំបានឃើញព្រះសង្ឃ ដែលគង់ចាំវស្សាក្នុងវត្តនេះបានរៀនសូត្រធម៌វិន័យបានប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា។

៣- ដោយហេតុយើងខ្ញុំបានឃើញវត្តនេះ កំពុងមានការកសាងទីសេនាសន ។

៤- ដោយហេតុយើងខ្ញុំគិតពិចារណាឃើញថា អាយុសង្ខាររបស់ខ្លួន

---

រួមជា ២ ហត្ថ ១ ចំអាម គឺថាត្រូវដាក់ចីវរកឋិនអោយនៅត្រង់ចន្លោះទីបំផុតបង្គុយខាងមុខរបស់លោកដើមអាសន៍ ត្រឹម ១ ហត្ថ ១ ចំអាម ។

(១)បើអ្នកដើមបុណ្យសូត្រខ្លួនឯងគុំបាច់ថាពាក្យក្នុងវង់ក្រចកនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បិនទៀងទាត់ឋិតថេរ ។

ទើបបានផ្ដើមធ្វើកឋិនទាននេះឡើង ដោយបានជូនដំណឹងដល់អស់លោកអ្នក ជាញាតិមិត្តជិតឆ្ងាយ អោយជួយអនុមោទនាផង អស់លោកអ្នកសប្បុរសញាតិមិត្តក៏បានជួយឧបត្ថម្ភ ដោយកម្លាំងធនធានខ្លះ កម្លាំងកាយវាចាខ្លះ អោយបានកើតជាកឋិនទានដ៏ឧឡារិកអធិកអាចមិឡើង ដូចព្រះករុណាគ្រប់ព្រះអង្គ នឹងអស់លោកអ្នកសប្បុរសទាំងឡាយបានទត បានទស្សនាឃើញជាក់ស្ដែងនេះ ។

យើងខ្ញុំមានសេចក្ដីត្រេកអរក្រៃពេក ចំពោះការដែលអស់លោកអ្នកសប្បុរស ជាញាតិមិត្តទាំងឡាយបានខ្វល់ខ្វាយជួយឧបត្ថម្ភដោយកាយវាចាចិត្ត នឹងបានចូលចាប់កុសលដោយធនធានព្រមទាំងបានជួយហែហមកឋិនទានមកផង យើងខ្ញុំសូមជូនចំណែកផលដែលកើតអំពីកឋិនទាននេះ ដល់អស់លោកអ្នកគ្រប់គ្នាអោយបានស្មើៗ គ្នា ហើយសូមអោយអស់លោកអ្នកបានប្រកបដោយពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ក្នុងជាតិនេះ និងបានសំរេចនូវសម្បត្តិសុខទាំង ៣ ប្រការគឺសម្បត្តិមនុស្ស សម្បត្តិទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

## ថ្នាក់ទី ៧ កិច្ចវេរសំពត់កឋិន :

លុះចប់សុន្ទរកថា ឧបាសកឧបាសិកាទាំងអស់អង្គុយបត់ជើងបែរមុខឆ្ពោះទៅព្រះសង្ឃ លើកដៃប្រណម្យឡើងហើយអ្នកដើមការ ឬអាចារ្យនាំសូត្រនមោ ៣ដង រួចវេរសំពត់កឋិន ៣លើក ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


លើកទី ១ ថា :

ឥមំ ទុស្សំ (១) កឋិនចីវរំ សង្ឃស្ស ទេម ។

លើកទី ២ ថា :

ទុតិយម្បិ ឥមំ ទុស្សំ ។ល។ ទេម ។

លើកទី ៣ ថា :

តតិយម្បិ ឥមំ ទុស្សំ ។ល។ ទេម ។

ប្រែលើកទី ១ ថា :

បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ល។ ដល់ព្រះសង្ឃជាគម្រប់ពីរដងផង ។

ប្រែទី ៣ ថា :

បពិត្រព្រះ ។ល។ ដល់ព្រះសង្ឃ ជាគម្រប់បីដងផង ។

កាលសំពត់កឋិនហើយគេវេរគ្រឿងបរិក្ខារជាបរិវារកឋិន៣លើកទៀត

លើកទី ១ ថា :

យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេម(១)។

លើកទី ២ ថា :

(៦) បើវេរថា វត្ថំ ក៏បានប្រែដូចគ្នា ។

(១) ពាក្យវេរសំពត់កឋិននឹងគ្រឿងបរិក្ខារជាបរិវារកឋិននេះ ស្រង់ពីសៀវភៅគិហិបដិបត្តិ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ទុតិយម្បិ យេនម្ហាកំ ។ ល ។ ទេម ។

លើកទី ៣ ថា :

តតិយម្បិ យេនម្ហាកំ ។ ល ។ ទេម ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃសង្ឃដ៏ចម្រើនអើយ រីកចិនិនៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ល។ អង្គនោះ ជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ល។ អង្គនោះ ជាគម្រប់បីដងផង ។

កាលវេរដោយវាចា ហើយគប្បីដឹកលស់សំពត់កឋិននៅចំពោះមុខព្រះសង្ឃ ក្នុងហត្ថបាស គឺប្រវែង ២ហត្ថ ១ ចំអាមពីរលោកមិនបាចប្រគេនដោយដៃទេ ព្រោះក្នុងវិន័យមានចែងថា គប្បីប្រគេនតែដោយវាចា មិនគប្បីប្រគេនដោយកាយឡើយ ។

កាលទាយកវេរសំពត់កឋិន ព្រមទាំងគ្រឿងបរិក្ខារជាបរិវារកឋិនហើយ ព្រះសង្ឃលោកទទួលដោយតុណ្ហីភាព ហើយលោកសូត្រធម៌អនុមោទនាដោយគាថាផ្សេងៗ មានគាថាសំដែងពីកាលទានជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



លោកអនុមោទនាចប់ហើយ ឧបាសកគប្បីចូលទៅប្រគេនគ្រឿងបរិក្ខារជាបរិវារកឋិន ដល់ព្រះសង្ឃគ្រប់អង្គ តាមលំដាប់លំដោយដរាបដល់អស់សព្វគ្រប់ហើយ អ្នកដើមការបុណ្យឬតំណាង គប្បីបវារណាបច្ច័យ ជាលទ្ធផលនៃបុណ្យកឋិនចំពោះព្រះសង្ឃ ។ ឯបច្ច័យជាលទ្ធផលនៃបុណ្យនោះ គប្បីចែកជា ២ចំណែក, ចំណែក ១ប្រគេនចំពោះព្រះសង្ឃគ្រប់អង្គ, ចំណែក ១ទៀតចំពោះការកសាងក្នុងអារាម។

ចំណែកបច្ច័យដែលប្រគេនចំពោះព្រះសង្ឃ គប្បីបវារណាតាមពាក្យបវារណាដូចក្នុងពិធីចម្រើនព្រះបរិត្តឯណោះ គ្រាន់តែចែកជាចំណែក ១ តាមថ្នាក់លោកអ្នកក្រាលគ្រងលោកអ្នកសូត្រញត្តិ លោកបរិស័ទអ្នកគង់ហត្ថបាសលោកសាមណេរតាមចំនួនច្រើនតិចជាលំដាប់ប៉ុណ្ណោះ ។

ចំណែកបច្ច័យដែលបម្រុងទុកកសាងអ្វី ក្នុងអារាមនោះគប្បីបវារ-ណាដូចតទៅនេះ ÷

## ពាក្យបវារណាបច្ច័យកឋិន

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លាបានហែកឋិនមក ។ លទ្ធផលនៃកឋិនទាននេះបានបច្ច័យចំនួន (..(១)..) រៀល សូមបវារណាចំពោះព្រះសង្ឃ ដើម្បីកសាងនូវ (..(២)..) ក្នុងអារាមនេះ យើងខ្ញុំបានប្រគល់បច្ច័យចំនួន (..(១)..) រៀលនេះ ដល់

---

(១) គប្បីបញ្ចូលតាមចំនួនបច្ច័យ ។

(២) គប្បីបញ្ចូលតាមឈ្មោះវត្ថុដែលកសាង ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


គណៈកម្មការវត្តសម្រាប់កសាងនូវ (..(២)..) នេះ បើព្រះសង្ឃត្រូវការកសាងវេលាណា សូមឱ្យគណៈកម្មការវត្តចាត់ចែងប្រគេនដរាបដល់អស់បច្ច័យនេះចុះ ដើម្បីសេចក្តីសុខសេចក្តីចម្រើន ដល់យើងខ្ញុំទាំងឡាយផងអស់កាលជាអង្វែងទៅហោង (៣) ។

ថ្នាក់ទី ៨ កិច្ចឧទ្ទិសផល

បន្ទាប់ពីបវារណា ពីប្រគល់បច្ច័យដល់គណៈកម្មការមកគប្បីនាំគ្នាសូត្រយំកិញ្ចិឧទ្ទិសផល (១) ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យកឋិនត្រឹមប៉ុណ្ណោះ ។

## ៨. ពិធីបុណ្យផ្កា

ការបុណ្យដែលធ្វើដោយមានផ្កាជាសម្ភារៈ ហៅថាបុណ្យផ្កា បុណ្យផ្កាមាន ២យ៉ាង គឺ÷

១. បុណ្យផ្ការុក្ខជាតិ នឹងផ្កាវារីជាតិ គឺគេបេះផ្កាឈើនឹងផ្កាឈូកថ្វាយព្រះពុទ្ធរូប

២. បុណ្យផ្កាប្រាក់ គឺគេសន្ធូតប្រាក់ជាផ្កាបវារណាចំពោះព្រះសង្ឃដើម្បីសាងអ្វីមួយ ។

ប្រទេសខ្មែរសម័យបុរាណ ពុទ្ធបរិស័ទទាំងព្រះរាជា ទាំងប្រជារាស្ត្រតែងទ្រង់ធ្វើ តែងធ្វើបុណ្យផ្ការុក្ខជាតិ នឹងផ្កាវារីជាតិយ៉ាងឧឡារិក គឺប្រជា-

---

(៣) ពាក្យបវារណានេះត្រូវថាតែម្នាក់ មិនមែនវេរទេ ។

(១) ពាក្យយំកិញ្ចិឧទ្ទិសផល គប្បីយកតាមពិធីចម្រើនព្រះបរិត្តងណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



រាស្ត្រតែងធ្វើនៅខែប្រាំង រវាងខែមាឃផល្គុនចេត្រ គេនាំគ្នាបេះផ្កាឫក្ខជាតិនឹងវារីជាត មានផ្កាម្លិះនឹងផ្កាឈូកជាដើម យកមកចងក្រង បែរទៅថ្វាយព្រះពុទ្ធរូបនៅព្រះវិហារវត្តជិតគ្នា ព្រះរាជាតែងទ្រង់ធ្វើនៅខែវស្សា គឺក្នុងថ្ងៃ១៥កើតខែស្រាពណ៍ ដោយទ្រង់ស្ដេចយាងទៅក្រសាលបឹងតាម ព្រះទីនាំងនាវា ទ្រង់ព្រះរាជបញ្ជាបេះផ្កាឈូកស ឈូកក្រហម ព្រលិត លំចង់ ស្មៀងផ្កាយកមកថ្វាយព្រះ ក្នុងព្រះរាជមន្ទីរ ហើយនឹងទ្រង់ចាត់ឱ្យហែដោយក្បួនហែដ៏មហោឡារិក ទៅថ្វាយព្រះពុទ្ធបដិមាករ គ្រប់ព្រះអារាមហ្លួង ហៅថាព្រះរាជពិធីបេះផ្កាឈូកថ្វាយព្រះ (១) ។

ចំណែកពិធីរាស្ត្រ តាមដែលធ្លាប់បានឃើញមក អ្នកស្រុកខ្លះគេបេះផ្ការុកជាតិមានម្លិះរួតម្លិះលាជាដើម នឹងផ្កាវារីជាតិមានឈូកសឈូកក្រហមព្រលិតលំចង់ជាដើម មកចងក្រងជាកម្រងជាភ្ញួងព្រមទាំងអាហារូបករណ៍ជាអាទិ គឺចេក អំបុក នឹងគ្រឿងសម្ភារៈផ្សេងៗ ដង្ហែទៅចូលវត្តនៅជិតគ្នាដែលធ្លាប់ទាក់ទងគ្នា ហើយយកផ្កាទាំងនោះ ទៅថ្វាយព្រះពុទ្ធរូបក្នុងព្រះវិហារវត្តនោះ ក្រោយពីថ្វាយបង្គំព្រះហើយ គេនិមន្តសាមណេរ ១ ឬ ២អង្គសូត្រថ្វាយផ្កាថា «បុប្ផំ មក្រពុំរិក មានចិត្តត្រេកកាច់មកថ្វាយបុប្ផំមក្រពុំថ្វាយបន្ទន់កាយកបកេសរ ។ ល ។» ដូច្នេះជាដើមចប់ហើយ អ្នកស្រុកជើងវត្តគេរៀបភោជនាហារទទួលភ្ញៀវ ។ បន្ទាប់ពីនោះ គេឈប់សម្រាក ហើយនៅពេលត្រជាក់ មុននឹងលាគ្នាទៅវិញ ទាំងអ្នកស្រុកជើងវត្ត ទាំងអ្នកភ្ញៀវ

---

(១) បើចង់ជ្រាបរឿងនេះ សូមមើលក្នុងព្រះរាជពិធីទ្វាទសមាសភាគ ៣ របស់ពុទ្ធសាសនាបណ្ឌិត្យ ត្រង់ព្រះរាជពិធីនៅខែស្រាពណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


គណៈកម្មការវត្តសម្រាប់កសាងនូវ (..(២)..) នេះ បើព្រះសង្ឃត្រូវការកសាងវេលាណា សូមឱ្យគណៈកម្មការវត្តចាត់ចែងប្រគេនជរាបដល់អស់បច្ច័យនេះចុះ ដើម្បីសេចក្តីសុខសេចក្តីចម្រើន ដល់យើងខ្ញុំទាំងឡាយផងអស់កាលជាអង្វែងទៅហោង (៣) ។

ថ្នាក់ទី ៨ កិច្ចឧទ្ទិសផល

បន្ទាប់ពីបវារណា ពីប្រគល់បច្ច័យដល់គណៈកម្មការមកគប្បីនាំគ្នាសូត្រយំកិច្ចឧទ្ទិសផល (១) ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យកឋិនត្រឹមប៉ុណ្ណោះ ។

## ៨. ពិធីបុណ្យផ្កា

ការបុណ្យដែលធ្វើដោយមានផ្កាជាសម្ភារៈ ហៅថាបុណ្យផ្កា បុណ្យផ្កាមាន ២យ៉ាង គឺ÷

១. បុណ្យផ្ការុក្ខជាតិ នឹងផ្កាវារីជាតិ គឺគេបេះផ្កាឈើនឹងផ្កាឈូកថ្វាយព្រះពុទ្ធរូប

២. បុណ្យផ្កាប្រាក់ គឺគេសន្ទូតប្រាក់ជាផ្កាបវារណាចំពោះព្រះសង្ឃដើម្បីសាងអ្វីមួយ ។

ប្រទេសខ្មែរសម័យបុរាណ ពុទ្ធបរិស័ទទាំងព្រះរាជា ទាំងប្រជារាស្ត្រតែងទ្រង់ធ្វើ តែងធ្វើបុណ្យផ្ការុក្ខជាតិ នឹងផ្កាវារីជាតិយ៉ាងឧឡារិក គឺប្រជា-

---

(៣) ពាក្យបវារណានេះត្រូវថាតែម្នាក់ មិនមែនវេរទេ ។

(១) ពាក្យយំកិច្ចឧទ្ទិសផល គប្បីយកតាមពិធីចម្រើនព្រះបរិត្តឯណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



រាស្ត្រតែងធ្វើនៅខែប្រាំង រវាងខែមាឃផល្គុនចេត្រ គេនាំគ្នាបេះផ្ការុក្ខជាតិ នឹងវារីជាត មានផ្កាម្លិះនឹងផ្កាឈូកជាដើម យកមកចងក្រង បែរទៅថ្វាយព្រះពុទ្ធរូបនៅព្រះវិហារវត្តជិតគ្នា ព្រះរាជាតែងទ្រង់ធ្វើនៅខែវស្សា គឺក្នុងថ្ងៃ ១៥កើតខែស្រាពណ៍ ដោយទ្រង់ស្តេចយាងទៅក្រសាលបឹងតាម ព្រះទីនាំងនាវា ទ្រង់ព្រះរាជបញ្ជាបេះផ្កាឈូកស ឈូកក្រហម ព្រលិត លំចង់ ស្បៃក្តជ យកមកថ្វាយព្រះ ក្នុងព្រះរាជមន្ទីរ ហើយនឹងទ្រង់ចាត់ឱ្យហែដោយក្បួនហែដ៏មហោឡារិក ទៅថ្វាយព្រះពុទ្ធបដិមាករ គ្រប់ព្រះអារាមហ្លួង ហៅថា ព្រះរាជពិធីបេះផ្កាឈូកថ្វាយព្រះ (១) ។

ចំណែកពិធីរាស្ត្រ តាមដែលធ្លាប់បានឃើញមក អ្នកស្រុកខ្លះគេបេះផ្ការុកជាតិមានម្លិះរួតម្លិះលាជាដើម នឹងផ្កាវារីជាតិមានឈូកសឈូកក្រហម ព្រលិតលំចង់ជាដើម មកចងក្រងជាកម្រងជាភ្ញូងព្រមទាំងអាហារបករណ៍ជាអាទិ គឺចេក អំបុក នឹងគ្រឿងសម្ភារៈផ្សេងៗ ដង្ហែទៅចូលវត្តនៅជិតគ្នា ដែលធ្លាប់ទាក់ទងគ្នា ហើយយកផ្កាទាំងនោះ ទៅថ្វាយព្រះពុទ្ធរូបក្នុងព្រះវិហារវត្តនោះ ក្រោយពីថ្វាយបង្គំព្រះហើយ គេនិមន្តសាមណេរ ១ ឬ ២អង្គសូត្រថ្វាយផ្កាថា «បុប្ផមុក្រពុំរិក មានចិត្តត្រេកអរកាចមកថ្វាយបុប្ផមក្រពុំថ្វាយបន្ទន់កាយកបកេសរ ។ ល ។» ដូច្នេះជាដើមចប់ហើយ អ្នកស្រុកជើងវត្តគេរៀបភោជនាហារទទួលភ្ញៀវ ។ បន្ទាប់ពីនោះ គេឈប់សម្រាក ហើយនៅពេលត្រជាក់ មុននឹងលាគ្នាទៅវិញ ទាំងអ្នកស្រុកជើងវត្ត ទាំងអ្នកភ្ញៀវ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



គេនាំគ្នាលេងល្បែងប្រជាប្រិយផ្សេងៗ មានល្បែងឈូងបុកកញ្ចារនឹងប្រប កែជាដើមយ៉ាងសប្បាយទាំងអស់គ្នា ហើយអ្នកហែផ្កាមកគេថ្វាយបង្គំលា ព្រះសង្ឃ សំពះលាអ្នកស្រុកជើងវត្តនោះត្រឡប់ទៅស្រុកវិញ ដោយនាំយក ទាំងសេចក្ដីសប្បាយទៅផង ។

តាមការស្រាវជ្រាវ ពិធីបុណ្យផ្ការុក្ខជាតិនេះ មិនច្បាស់ជាកើតមាន ពីសតវត្សទីប៉ុន្មាន ឬរជ្ជកាលណាទេ ឃើញតែក្នុងព្រះរាជពង្សាវតារ ប្រទេសកម្ពុជា ថា «នៅរជ្ជកាលព្រះករុណាបរមកោដ្ឋ មានព្រះរាជពិធីបេះ ផ្កាឈូកថ្វាយព្រះក្នុងព្រះអារាម ហ្លួង» ហើយនឹងក្នុងសាស្ត្រាស្លឹករឹតរឿង ស្ដេចក្មេងថា «សម័យព្រេងនាយ មានក្មេងឃ្វាលគោ ១ក្រុម បាននាំគ្នាបេះ ផ្កាឈើផ្សេងៗ ដង្ហែទៅថ្វាយព្រះពុទ្ធរូប នៅព្រះវិហារវត្តមួយ ក្រោយពីនោះ ក្មេង ជាមេបានជាស្ដេច ។ល។

តាមរឿងនេះ ឃើញថា នៅប្រទេសខ្មែរយើង សម័យបុរាណ មាន ធ្វើបុណ្យផ្ការុក្ខជាតិធំដុំជាច់ដោយឡែក តែក្នុងសម័យបច្ចុប្បន្ន ឃើញធ្វើតែ បន្តិចបន្តួចជាមួយនឹងផ្កាប្រាក់ដោយគេសន្មតបុណ្យផ្កាប្រាក់ ជាបុណ្យធំដុំ ព្រោះរួបរួមបច្ច័យកសាងថាវរវត្ថុផ្សេងៗ ទាំងខាងពុទ្ធចក្រទាំងខាងអាណា- ចក្រជាការកសាងសាសនានឹងប្រទេសជាតិឱ្យរុងរឿង ។

គម្ពីរបាលីមុត្តកវិនិច្ឆ័យ ត្រង់ភេសជ្ជករណាទិវិនិច្ឆ័យកថា មានចែង ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ចប្រើនម្នាក់ឱ្យមកសួរថ្នាំ លោកមិនប្រាប់ថាចេះថាមិនចេះទេត្រឡប់ជាចរ-ចានឹងពួកភិក្ខុ «ម្នាលអាវុសោបើរោគដូចនេះ កើតឡើងដល់ភិក្ខុ តើគេតែងប្រកបថ្នាំអ្វី?» ពួកភិក្ខុបានទូលមកវិញថា «តែងយកថ្នាំនេះមួយៗ» ។ ស្ត្រីបម្រើបានពួក៏យកជំណឹងនោះទៅក្រាបទូលព្រះរាជា ។ ព្រះរាជា នឹងពួកសេវកាមាត្យបានជ្រាបសេចក្តីនោះ ក៏ចាត់ចែងថ្នាំនោះព្យាបាលរោគព្រះរាជទេពី ។ កាលរោគនោះជាសះស្បើយ ព្រះរាជានឹងសេវកាមាត្យ បានយកចីវរ ១ ត្រៃ នឹងប្រាក់ ៣០០ កហាបណៈដាក់ក្នុងប្រអប់ ១ នាំទៅដឹកល់ទុកទៀបបាទមូលនៃព្រះមហាទុមត្ថេរ ហើយបវារណាថា «ភន្តេ មុប្បបួជំ ករោថ បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើន ! សូមព្រះករុណាម្ចាស់ ចាត់ចែងផ្កាបូជា (ព្រះពុទ្ធរូប) ចុះ » ។ ព្រះមហាបទុមត្ថេរបានទទួលដោយតុណ្ហីភាព រួបគិតថា «រូបិយវត្ថុ ១ ចំណែកនេះជាចំណែកអាចារ្យ » ។ លុះគិតហើយទើបញ៉ាំងអាចារ្យនោះឱ្យទទួលយក នូវចំណែកនោះដោយកប្បិយវោហារ, សល់ពីនោះលោកចាត់ចែងផ្កាបូជាព្រះពុទ្ធរូប ។

ប្រហែលជាពុទ្ធសាសនិកជន យកតម្រាបតាមរឿងនេះ បានជាគេធ្វើបុណ្យផ្ការុក្ខជាតិ នឹងផ្កាប្រាក់ ជាពុទ្ធបូជាជាប់ជាប្រពៃណីរៀងមក ហើយអ្នកមានសទ្ធាចង់សាងថាវរវត្ថុមានកុដិ វិហារសាលាបុណ្យ សាលារៀនស្ពាន ស្រះជាដើម ដែលជារបស់ត្រូវចាយប្រាក់រាប់ពាន់រាប់ម៉ឺន តែធនធានខ្លួនមានតិច មិនអាចសាងម្នាក់ឯងកើត ក៏ផ្តើមជាបុណ្យផ្កាឡើង ដើម្បីអង្គាសប្រាក់ញាតិមិត្តឱ្យចូលជួយកសាងថាវរវត្ថុនោះ ៗ តាមកម្លាំងសទ្ធាផង, តែតាមទម្លាប់ស្រុកយើង ទោះបីអ្នកមានធនធានច្រើនដែលអាចកសាងតែ-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ម្នាក់ឯងបាន ក៏តែងផ្សាយដំណឹងបុណ្យនោះដល់ញាតិមិត្តជិតឆ្ងាយ ឱ្យជួយឧបត្ថម្ភផង ។ ឯជនដ៏មានសទ្ធាជ្រះថ្លាក៏ជួយចាប់កុសលជាច្រើននាក់ បានប្រាក់ច្រើនពាន់ច្រើនម៉ឺនរៀល ។

## កាតព្វកិច្ចនៃបុណ្យផ្កា

របៀបបុណ្យផ្កាដែលធ្វើក្នុងបច្ចុប្បន្នកាល មាន ២យ៉ាង គឺ បុណ្យផ្កាមានពិធីហែ ១យ៉ាង បុណ្យផ្កាឥតពិធីហែ ១យ៉ាង ។

ឯបុណ្យផ្កាមានពិធីហែ គេចាត់ចែងធ្វើដោយកាតព្វកិច្ច ៧ថ្នាក់គឺ ÷

១. កិច្ចសុំវត្តលោកហែចូល

២. កិច្ចផ្សាយដំណឹងបុណ្យផ្កា

៣. កិច្ចសូត្រព្រះបរិត្ត- ទេសនា

៤. កិច្ចដង្ហែ

៥. កិច្ចសូត្រសុន្ទរកថា

៦. កិច្ចបវារណាបច្ច័យផ្កា

៧. កិច្ចឧទ្ទិសផល

### ថ្នាក់ទី ១ កិច្ចសុំវត្តលោកហែចូល

ទាយកដែលមានសទ្ធា កាលបើគេត្រូវការហែផ្កាទៅចូលវត្តណាដើម្បីកសាងសេនាសនៈឬអ្វីៗ គេតែងទៅទូលលោកគ្រូចៅអធិការវត្តនោះឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ជ្រាបជាមុន ថាខ្លួននឹងហែផ្កាមកចូលនៅថ្ងៃខែណា តាមដែលគេត្រូវការធ្វើ ហើយគេហែទៅចូលតាមកាលបរិច្ឆេទនោះ ។

## ថ្នាក់ទី ២ កិច្ចផ្សាយដំណឹងបុណ្យផ្កា

លុះទូលលោកហើយ សម័យបុរាណគេប្រាប់ញាតិដោយមាត់ទទេ, សម័យបច្ចុប្បន្ន គេចាត់ចែងបោះពុម្ពសេចក្ដីជូនដំណឹងបុណ្យនោះ ដូចមានជាគំរូខាងមុខនេះ ។

## ដំណឹងបុណ្យផ្កា

យើងខ្ញុំដូចមាននាមខាងក្រោម សូមជំរាបអស់លោកអ្នកទាំងឡាយ

សូមជ្រាប ។

យើងខ្ញុំបានឃើញវត្ត. . . . នៅឃុំ. . . . ស្រុក. . . . ខែត្រ. . . . មានសាលារៀនបាលី រៀនធម៌វិន័យ មានភិក្ខុរៀនសូត្រជាច្រើនអង្គ តែមានព្រះវិហារចាស់ទ្រុឌទ្រោម ក៏មានសេចក្ដីសង្វេគជ្រះថ្លាឡើង បានសម្រេចចិត្ត ថានឹងចំណាយធនធានជួសជុលព្រះវិហារនោះ តែដោយយើងខ្ញុំមានធនធានមិនល្មមនឹងចំណាយជួសជុលនោះ ទើបផ្ដើមធ្វើបុណ្យផ្កានេះឡើង ដើម្បីឱ្យអស់លោក អ្នកសប្បុរសជួយឧបត្ថម្ភផង ។

## កម្មវិធីបុណ្យ

វេលាម៉ោង ៨យប់ ថ្ងៃទី. . . ខែ. . . ឆ្នាំ ១៩. .(១) ចម្រើនព្រះបរិត្ត រួចទេសនា នៅទី (គេហដ្ឋាននៃយើងខ្ញុំ) -

(១) ត្រូវដាក់ថ្ងៃខែឆ្នាំតាមពេលដែលធ្វើ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


(២) ក្នុងឃុំ. . . . ស្រុក. . . . ខេត្ត. . . . ។

ថ្ងៃទី. . . . ខែឆ្នាំដដែល វេលាម៉ោង. . . . . ដង្ហែរអង្គផ្កាចេញពីគេហដ្ឋាននោះ ទៅកាន់វត្តនោះ ដើម្បីបវារណាបច្ច័យដល់ព្រះសង្ឃ ។

សូមអស់លោកអ្នកជួយឧបត្ថម្ភបុណ្យនេះតាមសទ្ធា ។

អ្នកផ្តើមបុណ្យ

. . . . . . . . . . . . . . . . . . . . . . . . . . . . . . (៣) ។

## ថ្នាក់ទី ៣ កិច្ចសូត្រព្រះបរិត្ត- ទេសនា

បុណ្យផ្កាដែលមានពិធីហែ គេតែងធ្វើសង្សឹក ១ ទំហំប្រមាណ ១ម៉ែត្រ ៤ជ្រុង ក្រាលដោយរនាបឬស្សីឬក្តារ មានតារាងកំពស់ ២តឹក ព័ទ្ធជុំវិញ មានជើង ៤កំពស់ ៣តឹក សម្រាប់ដាក់គ្រឿងសក្ការៈ ជាអាទិ គឺផ្កាប្រាក់ ដែលគេយកផ្លែដូងមកវៀលក្រឡឹងក្បាលដោតក្រដាសប្រាក់ ឬកាត់ដើមចេកជាកង់ៗ ប្រវែង ១តឹក ដោតផ្កាក្រដាសផ្កាបួទុមជាត ។ នៅពេលចម្រើនព្រះបរិត្ត គេយកសង្សឹកនឹងផ្កាប្រាក់ផ្កាក្រដាសនោះ ទៅដំកល់នៅទីសន្និបាត ។

កាលពុទ្ធបរិស័ទមកកាន់ទីសន្និបាតបុណ្យហើយ អ្នកដើមបុណ្យត្រូវយកសៀវភៅសរសេរ ១ ទឹកខ្មៅ ១ដប ដងប៉ាកកា ១ ថ្លិលជើងធំ ១ មកដំកល់លើតុ ១ ព្រមទាំងកៅអី ៣- ៤ យកទៅដំកល់ទុកនៅទីដ៏សមគួរ -

---

(២) ត្រូវដាក់តាមកន្លែងដែលធ្វើ ។

(៣) ត្រូវដាក់ឈ្មោះអ្នកផ្តើមបុណ្យ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ហើយរកមនុស្ស ៣នាក់អោយទៅអង្គុយនៅកៅអីនោះ ម្នាក់សម្រាប់កត់ឈ្មោះនឹងចំនួនប្រាក់ដែលគេចូលបុណ្យ ពីរនាក់ទៀត សម្រាប់ទទួលប្រាក់អំពីអ្នកចូលបុណ្យ ។ កាលគេចូលបុណ្យរួចរាល់ហើយ ជនទាំង ៣នាក់នោះត្រូវរាប់ប្រាក់ផ្ទៀបនឹងបញ្ជី បើឃើញត្រូវគ្នាហើយ ត្រូវប្រគល់ឱ្យទៅអ្នកដើមបុណ្យ ។

ខណៈនោះ អ្នកដើមបុណ្យ ឬអាចារ្យ ត្រូវនាំពួកឧបាសក ឧបាសិកា នមស្សការព្រះរតនត្រ័យ សមាទានសីលហើយអារាធនាព្រះបរិត្ត ចប់ព្រះបរិត្តហើយ និមន្តព្រះធម្មកថិកសំដែងធម៌ចប់ធម៌ហើយ ត្រូវសូត្រយំកិញ្ចិ ឧទ្ទិសផល (១) ។

## ថ្នាក់ទី ៤ កិច្ចដង្ហែផ្កា

ព្រឹកឡើងត្រូវរៀបក្បួនដង្ហែចេញពីព្រលឹម បើផ្លូវគោកហែដោយរថយន្ត ផ្លូវទឹកដោយកប៉ាល, លុះដល់ទៅវត្តដែលត្រូវការនោះ ត្រូវនាំគ្នាហែអង្គផ្កាប្រទក្សិណព្រះវិហារ ៣ ជុំហើយចូលទៅក្នុងព្រះវិហារ ដាក់អង្គផ្កា នឹងទេយ្យវត្ថុជាបរិក្ខារដែលហែមកនោះ ចំពោះព្រះភក្ត្រព្រះពុទ្ធរូបនឹងព្រះសង្ឃដែលគង់ចាំនៅនោះស្រាប់ ហើយត្រូវថ្វាយបង្គំព្រះសមាទានសីល

## ថ្នាក់ទី ៥ កិច្ចសូត្រសុន្ទរកថា

កាលចប់កិច្ចថ្វាយបង្គំព្រះសមាទានសីលហើយ អ្នកដើមការបុណ្យ

(១) ពាក្យនមស្សការ- សមាទានសីល- អារាធនាព្រះបរិត្តនឹងឧទ្ទិសផលសូមយកតាមពិធីចម្រើនព្រះបរិត្ត ឯពាក្យអារាធនាធម៌ទេសនាសូមយកតាមពិធីបុណ្យកឋិន ។

www.budhist.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ឬអាចារ្យក្រោកឈរឡើងថ្លែងសុន្ទរកថាពណ៌នា អំពីបុព្វហេតុនៃបុណ្យផ្កា នោះដូចតទៅនេះ ÷

## សុន្ទរកថាបុណ្យផ្កា

បពិត្រព្រះករុណាគ្រប់ព្រះអង្គ អស់លោក- អ្នកសប្បុរសទាំងឡាយ។

ខ្ញុំព្រះករុណា ខ្ញុំ (តាងនាមអ្នកដើមការបុណ្យ ) (១) សូមឱកាសពណ៌នាអំពីបុណ្យ ហេតុនៃបុណ្យផ្កានេះ ដូចតទៅ÷

យើងខ្ញុំទាំងឡាយ មានសេចក្តីជ្រះថ្លាពន់ពេក ដោយបានដឹងថាព្រះសង្ឃវត្តនេះ លោកសិក្សាព្រះបរិយត្តិធម៌ .នឹងប្រព្រឹត្តធម៌វិន័យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិនឹងពុទ្ធានុញ្ញាត តែមានសេចក្តីសង្វេគជាខ្លាំង ដោយបានឃើញ (ព្រះវិហារវត្តនេះចាស់ទ្រុឌទ្រោម) ។ សេចក្តីជ្រះថ្លា នឹងសេចក្តីសង្វេគនេះហើយ ដែលបណ្តាលអោយយើងខ្ញុំហែអង្គផ្កានេះមក ដើម្បីជួយឧបត្ថម្ភការ (ជួសជុលព្រះវិហារនេះឱ្យបានមាំទាំឡើងវិញសម្រាប់ព្រះសង្ឃធ្វើសង្ឃកម្មតទៅ) ។

អង្គផ្កានេះ កើតឡើងដោយកម្លាំងសាមគ្គីធម៌របស់យើងខ្ញុំដែលរួមចិត្តគំនិតគ្នាផ្តើមឡើង ដោយសេចក្តីជ្រះថ្លានឹងសេចក្តីសង្វេគដូចពណ៌នាមក យើងខ្ញុំសូមឧទ្ទិសផលនៃកុសលនេះ ជូនដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម សូមលោកបានសម្រេចសម្បត្តិមនុស្ស សម្បត្តិសួគ៌ នឹងសម្បត្តិព្រះនិព្វាន ហើយយើងខ្ញុំសូមប្រគេនជូននូវភាគផលនៃ -

(១) បើអ្នកដើមបុណ្យសូត្រខ្លួនឯង ពុំបាច់ថាពាក្យក្នុងវង់ក្រចកនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


កុសលនេះ ដល់ព្រះករុណាគ្រប់ព្រះអង្គ ដល់អស់លោកអ្នកសប្បុរសទាំងឡាយ ដែលមានសទ្ធាជ្រះថ្លាបានជួយផ្តល់នូវការកុសលនេះ ដោយកម្លាំងទ្រព្យ នឹងកម្លាំងកាយវាចា ឱ្យបានជាបុណ្យដ៏ឧឡារិកនេះឡើង សូមព្រះករុណាគ្រប់ព្រះអង្គ នឹងអស់លោកអ្នកសម្បុរសគ្រប់គ្នា បានផលានិសង្ស ស្មើៗគ្នា ហើយសូមឱ្យសម្រេច នូវពរទាំង ៤ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ ក្នុងលោកនេះ នឹងសូមបានសម្រេចនូវសម្បត្តិមនុស្ស សម្បត្តិទេវតា ក្នុងលោកខាងមុខ ហើយក្នុងអវសានជាតិ សូមបានសម្រេចព្រះនិព្វាន សមគួរតាមសេចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

## ថ្នាក់ ៦ កិច្ចបវារណាបច្ច័យផ្កា

កាលចប់សុន្ទរកថាហើយ អ្នកដើមការបុណ្យ ឬអ្នកតំណាងត្រូវបវារណាបច្ច័យផ្កាចំពោះព្រះសង្ឃ នឹងចំពោះគណៈកម្មការវត្ត ពុទ្ធបរិស័ទទាំងពួងថាតាមដូចខាងក្រោមនេះ ÷

## ពាក្យបវារណាបច្ច័យផ្កា

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ មានសទ្ធាជ្រះថ្លាប្រមូលនូវផ្កាគឺហិរញ្ញវត្ថុបានចំនួន..... ប៉ុណ្ណេះ សូមបវារណាចំពោះព្រះសង្ឃ ដើម្បីកសាងនូវព្រះវិហារក្នុងអារាមនេះ យើងខ្ញុំបានប្រគល់បច្ច័យផ្កាចំនួន..... នេះជូនគណៈកម្មការវត្តឱ្យទុក សម្រាប់កសាងព្រះវិហារនេះ បើព្រះសង្ឃត្រូវការសាងវេលាណា សូមអោយគណៈកម្មការវត្តចាត់ចែងកសាងប្រគេនដរាបដល់អស់បច្ច័យនេះចុះ ដើម្បីសេចក្តីសុខ សេចក្តី-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ចំម្រើនដល់លោកអ្នកមានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង (១) ។

កាលឧបាសកបវារណាបច្ច័យហើយ ព្រះសង្ឃក៏សូត្រអនុមោទនាតាមគួរដល់ទាន នឹងកាលវេលា ។

## ថ្នាក់ទី ៧ ជាកិច្ចឧទ្ទិសផល

កាលព្រះសង្ឃអនុមោទនាចប់ហើយ ឧបាសកក្រូវសូត្រយំកិញ្ចិឧទ្ទិសផល ។

បុណ្យផ្កាមានពិធីហែ មានរបៀបចាត់ការជា ៧ថ្នាក់ ដូចរៀបរាប់មកនេះ ។

ឯបុណ្យផ្កាឥតពិធីហែ មានរបៀបចាត់ការតែ ៦ថ្នាក់ គឺ ÷

១• កិច្ចសុំវត្តហែចូល

២• កិច្ចផ្សាយដំណឹងបុណ្យ

៣• កិច្ចសូត្រព្រះបរិត្ត- ទេសនា

៤• កិច្ចសូត្រសុន្ទរកថា

៥• កិច្ចបវារណាបច្ច័យ

៦• កិច្ចឧទ្ទិសផល

(១) បច្ច័យផ្កានោះ គប្បីបវារណាជា ២យ៉ាង បវារណាចំពោះលោកគ្រប់អង្គ ១យ៉ាង ចំពោះការកសាងជាសាធារណៈ ១យ៉ាង ។ ពាក្យបវារណាចំពោះលោកគ្រប់អង្គ សូមយកតាមពាក្យបវារណាក្នុងពិធីចម្រើនព្រះបរិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


សូមជ្រាបថា បុណ្យផ្កាឥតពិធីហែ មានកិច្ចត្រូវសុំវត្តហែចូល ត្រូវផ្សាយដំណឹងមនុស្ស ត្រូវសូត្រព្រះបរិត្តទេសនា, ត្រូវសូត្រសុន្ទរកថា ត្រូវបវារណាបច្ច័យផ្កា នឹងត្រូវឧទ្ទិសផល ដូចបុណ្យផ្កាមានពិធីហែដែរ ប្លែកតែមិនហែ ប៉ុណ្ណោះ ពីព្រោះបុណ្យផ្កាបែបនេះ គេប្រជុំគ្នាធ្វើនៅទីវត្ត ដែលត្រូវការចូលនោះ ហើយគេបវារណាបច្ច័យចំពោះព្រះសង្ឃនៅវត្តនោះតែម្តង ឬមួយគេនិមន្តព្រះសង្ឃពីវត្តដែលត្រូវការចូលនោះ មកទទួលបច្ច័យផ្កានៅផ្ទះគេ ជាការស្រេច តែម្តង ។

កាលឧបាសកបវារណាបច្ច័យ ព្រះសង្ឃអនុមោទនាហើយ គប្បីនាំគ្នាសូត្រយំកិញ្ចិឧទ្ទិសផលជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យផ្កាត្រឹមប៉ុណ្ណោះ ។

## ៩. ពិធីបុណ្យបច្ច័យ ៤

ការបុណ្យដែលធ្វើដោយវេរបច្ច័យ (គ្រឿងអាស្រ័យរបស់បព្វជិត) គ្រប់ទាំង ៤មុខ ប្រគេនព្រះសង្ឃហៅថាបុណ្យបច្ច័យ ៤ ។

បច្ច័យ ៤ គឺអ្វីខ្លះ ? បច្ច័យ ៤ គឺ ÷

១. គ្រឿងស្លៀកដណ្តប់ គឺស្បង់ចីពរ សង្ឃាដី អង្សក វត្ថពន្ធ កាយពន្ធ កន្សែងដណ្តប់ កន្សែងជូតមុខ កន្សែងជូតដៃជាដើម រហូតដល់សំពត់បិទបួសរុំដំបៅ ទទឹង៤ធ្នាប់ បណ្តោយ ៨ធ្នាប់ ជាទីបំផុត ហៅថា ចីវរប្បច្ច័យ

២. គ្រឿងឆាន់ គឺបាយ សម្ល ម្ហូបគ្រៀម ម្ហូបស្រស់ ប្រហុក ផ្អក អំបិល ត្រីងៀត ត្រីឆ្អើរ ជាដើម ព្រមទាំងគ្រឿងប្រដាប់សម្រាប់ដាក់ចង្ហាន់

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


មានស្លាបព្រា ចានថូ ចានស្រោក់ តុ ថាសជាដើម ហៅថា បិណ្ឌបាតប្បច្ច័យ

៣. គ្រឿងដេកអង្គុយ មានកន្ទេល ខ្នើយ មុង ឆ័ត្រ ស្បែកជើង កុដិ សាលា វិហារ តុ កៅអី ជាដើម ហៅថាសេនាសនប្បច្ច័យ ។

៤. គ្រឿងថ្នាំព្យាបាលជម្ងឺ មានថ្នាំបុក គល្លិកា ក្រមួន កុឡា ប្រេងខ្យល់ ថ្នាំជក់ ថ្នាំរិត ថ្នាំលាប ថ្នាំចាក់ តែ ស្ករ ស្លា បារីជាដើម ហៅថាគិលានភេសជ្ជប្បច្ច័យ ។

ទាយកដែលត្រូវការធ្វើបុណ្យបច្ច័យ ៤ ត្រូវធ្វើគ្រប់ទាំង ៤មុខ គឺគប្បីលៃធ្វើតាមសមត្ថភាពរបស់ខ្លួន បើអាចធ្វើប៉ុណ្ណាបានក៏ធ្វើប៉ុណ្ណោះ ទោះបីតិចតួច ឱ្យតែគ្រប់ទាំង ៤មុខ ដូចរៀបរាប់តទៅនេះ គឺ :

- ✧ មុខគ្រឿងចីវរ សូម្បីតែសាដក ១ ឬស្បង់ ១ ក៏បាន ។
- ✧ មុខគ្រឿងឆាន់ សូម្បីតែចង្ហាន់ ១ ឆ្នែតក៏បាន ។
- ✧ មុខគ្រឿងសេនាសនៈ សូម្បីតែកន្ទេល ១ ឬខ្នើយ ១ ក៏បាន ។
- ✧ មុខគ្រឿងភេសជ្ជៈ សូម្បីតែប្រេងខ្យល់ ១ដប ក៏បាន ។

សូមជ្រាបថា បើធ្វើតូច ក្នុងបច្ច័យមួយៗ ក៏តិច តែទោះបីតិច ក៏គប្បីឱ្យគ្រប់ ៤មុខ ដូចពោលមកហើយ បើអាចធ្វើធំកើយក្នុង ១មុខៗច្រើនបាន ក៏រឹតតែបានផលច្រើនតាមចំនួន ។

ដើម្បីអោយទាយកងាយយល់ ក្នុងកិច្ចធ្វើពិធីបុណ្យបច្ច័យ ៤ សូមពន្យល់របៀបធ្វើដូចតទៅនេះ ÷

សេវាមិត្តភាពកុំព្យូទ័រ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


## កាតព្វកិច្ចនៃបុណ្យបច្ច័យ ៤

ពិធីបុណ្យបច្ច័យ ៤ មានកិច្ចត្រូវចាត់ចែងធ្វើជា ៦ថ្នាក់ គឺ :

១. កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២. កិច្ចរៀបចំទីសេនាសនៈ នឹងទេយ្យទាន

៣. កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់មក

៤. កិច្ចនមស្សការព្រះរតនត្រ័យ - សមាទានសីល - សូត្រមន្ត- ទេសនា

៥. កិច្ចវេរបច្ច័យ ៤ នឹងប្រគេនទេយ្យទាន

៦. កិច្ចឧទ្ទិសផល

បណ្តាកិច្ចទាំង ៦ថ្នាក់នេះ ថ្នាក់ទី ១- ៣- ៤ នឹង ៦ ដូចកិច្ចសង្ឃទាន ប្លែកតែថ្នាក់ទី ២ នឹងទី ៥ ។ ដូច្នេះត្រង់ថ្នាក់ទី ១- ៣- ៤ នឹង ៦ សូមយកតាមពិធីសង្ឃទាននោះចុះ ។ ទីនេះសូមពណ៌នាតែថ្នាក់ទី ២ នឹងទី ៥ ដូចតទៅនេះ÷

### ថ្នាក់ទី ២ កិច្ចរៀបចំទីសេនាសនៈនឹងទេយ្យទាន

ការរៀបចំទីសេនាសនៈក្នុងពិធីបុណ្យបច្ច័យ ៤ ក៏ដូចក្នុងពិធីបុណ្យសង្ឃទានដែរ ប្លែកតែទេយ្យទាន គឺពិធីបុណ្យបច្ច័យ ៤នេះ ត្រូវរៀបចំបច្ច័យ ៤ គឺ÷

បើត្រូវធ្វើបច្ច័យធុនកណ្តាល ហើយបើនិមន្តលោក ៤អង្គ ត្រូវរៀប

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បច្ច័យនីមួយៗ ៤ ប្រដាប់សម្រាប់ប្រគេនលោក ១ប្រដាប់ ១អង្គ គឺ

១. មុខចីវរប្បច្ច័យ ឱ្យមានចីវរ ១ត្រៃ គឺស្បង់ចីពរ សង្ឃាដីក៏បាន តែ ១ សៀងគឺស្បង់១ ចីពរ ១ ក៏បាន តែស្បង់ ១ ឬសាដក ១ ក៏បាន ។

២. មុខបិណ្ឌបាតប្បច្ច័យ ឱ្យមានបាយនឹងម្ហូប បង្អែមព្រមទាំងអាហារូបករណ៍ មានចានថ្ម ចានស្រាក់ ស្លាបព្រា កំសៀវទឹក ថូទឹក កែវទឹកជាដើម ។

៣. មុខសេនាសនប្បច្ច័យ ឱ្យមានកន្ទេល ខ្នើយ មុង ឆត្រ ស្បែកជើងជាដើម ។

៤. មុខគិលានភេសជ្ជប្បច្ច័យ ឱ្យមានប្រេងខ្យល់ ប្រេងកុឡា តែ ស្ករ បារីជាដើម ។

ទាំង ៤មុខនេះ រៀបជា ១ប្រដាប់ ក្នុងប្រដាប់នីមួយៗ ឱ្យមានសៀវភៅធម៌ សៀវភៅសរសេរ ទឹកខ្មៅ ខ្មៅដៃ ដងប៉ាកកាព្រមទាំងស្លាប បន្ទាត់ ជ័រលុប ច្រាស់ដុសធ្មេញ ថ្នាំដុសធ្មេញជាដើម ។ រៀបហើយត្រូវខ្ចប់ដោយក្រដាសភ្លឺៗ ចងបូរជាក្បាច់រំលេចពណ៌ឱ្យល្អស្អាតហើយយកទាំង ៤ ប្រដាប់ នោះទៅដឹកលំចំពោះព្រះភក្ត្រព្រះសង្ឃទាំង ៤អង្គ នៅវេលាចម្រើនព្រះ-បរិត្ត ទេសនា ពីល្ងាចផង ព្រឹកឡើងពេលវេរផង ។

## ថ្នាក់ទី ៥ កិច្ចវេរបច្ច័យ ៤ នឹងប្រគេនទេយ្យទាន

ព្រឹកឡើងពេលម៉ោង ៨ ឬ ៩ ដែលព្រះសង្ឃនិមន្តមកដល់ហើយ ក្រោយពីនមស្សការព្រះរតនត្រ័យ សមាទានសីល អ្នកដើមការបុណ្យ ព្រម

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer



ទាំងញាតិមិត្តត្រូវនាំគ្នាកាន់គ្រឿងប្រដាប់បុណ្យឡើង ហើយអ្នកដើមបុណ្យ ឬអាចារ្យ តាំងនមោ ៣បទ រួចវេរបច្ច័យ ៤ បីលើក ដូចខាងមុខនេះ÷

លើកទី ១ ថា :

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស នេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទិឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែកលើកទី ១ ថា :

បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤ នេះមកដឹកល់ទុក ក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើនសូមព្រះសង្ឃទទួលបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង អស់វារៈពីរដងផង

ប្រែលើកទី ៣ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បពិត្រព្រះ ។ ល ។ ទៅហោង អស់វារៈបីដងផង វេររួចហើយ គប្បីយកទេយ្យទានទាំងនោះប្រគេនប្រដាប់ ១ អង្គគ្រប់ទាំង ៤អង្គ ។ ទាយកប្រគេនទេយ្យទានហើយ ព្រះសង្ឃអនុមោទនា ។ ចប់ហើយ ទាយកស្លូត្រយំកិច្ចិឧទ្ទិសផល ជាកិច្ចបង្ហើយបុណ្យ ។

ពិធីបុណ្យបច្ច័យ ៤ នឹងធ្វើប្រគេនភិក្ខុ ៤អង្គ ដូចពោលខាងលើនេះក៏បាន នឹងធ្វើប្រគេនភិក្ខុតែ ១អង្គក៏បាន ឯពិធីធ្វើប្រគេនភិក្ខុតែ ១អង្គក៏មាន ៦ថ្នាក់ដូចធ្វើប្រគេនភិក្ខុ ៤អង្គដែរប្លែកតែត្រង់ចំនួនប្រដាប់ គឺត្រូវរៀបតែ ១ប្រដាប់ សម្រាប់តែភិក្ខុ ១អង្គ ហើយនឹងប្លែកតែត្រង់បាលីវេរ ត្រូវវេរតាមរបៀបភិក្ខុ ១អង្គ ប៉ុណ្ណោះ ។

ឯរបៀបវេរប្រគេន ១អង្គនោះ ក្រោយពីនមោ ៣ដង ហើយត្រូវវេរ ៣លើក :

លើកទី ១ ថា :

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រែលើកទី ១ ថា :

បពិត្រព្រះករុណាដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤នេះ មកដឹកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះករុណាដ៏មានអាយុ បពិត្រព្រះករុណាដ៏ចម្រើនសូមព្រះករុណាដ៏មានអាយុ ទទួលយកនូវបច្ច័យទាំងឡាយ ៤នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង អស់វារៈបីដងផង ។

ទាយកវេរហើយប្រគេនទេយ្យទានដល់លោក កាលលោកទទួលអនុមោទនាចប់ហើយ ត្រូវស្លូត្រយំកិព្វិឧទ្ទិសផល ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យបច្ច័យ ៤ត្រឹមប៉ុណ្ណេះ ។

## ១០ . ពិធីបុណ្យវេរសាដកនៅរដូវចូលឆ្នាំ

ការបុណ្យដែលទាយកធ្វើដោយប្រគេនសំពត់ងូតទឹក ចំពោះព្រះសង្ឃ ហៅថា «បុណ្យវេរសាដក» ឬអ្នកខ្លះហៅថា «បុណ្យនិមន្តលោកឆាន់ប្រគេនសាដក» ព្រោះតាំងពីបុរាណកាលមក ពុទ្ធបរិស័ទជាតិខ្មែរ តែងនិមន្តព្រះសង្ឃឆាន់ ប្រគេនសាដក ស្រង់ទឹកព្រះសង្ឃ ស្រង់ព្រះ ផ្ងូតមាតាបិតាជីដូនជីតានៅរដូវចូលឆ្នាំគឺ រវាងខែចេត្រ នឹងពិសាខ ឬចំលើថ្ងៃចូលឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ទាំង ៣ ថ្ងៃ ឬថ្ងៃណាមួយ ។

បុណ្យនេះ អ្នកខ្លះគេទៅរៀបធ្វើនៅទីវត្ត អ្នកខ្លះគេធ្វើនៅផ្ទះទោះបីធ្វើនៅវត្តក្តី នៅផ្ទះក្តី ក៏មានពិធីត្រូវគ្នា ខុសតែទីកន្លែងប៉ុណ្ណោះ ។ ទីនេះសូមពណ៌នាតែពីរបៀបធ្វើនៅផ្ទះដូចតទៅ

## កាតព្វកិច្ចនៃបុណ្យវេរសាដក

បើធ្វើនៅផ្ទះ គេចាត់ការដោយកិច្ចមាន ៧ថ្នាក់ គឺ÷

១. កិច្ចធ្វើសាដក

២. កិច្ចនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

៣. កិច្ចរៀបចំទីសេនាសនៈ នឹងទេយ្យទាន

៤. កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់មក

៥. កិច្ចនមស្សការព្រះរតនត្រ័យ- សមាទានសីល សូត្រមន្តទេសនា ។

៦. កិច្ចវេរសាដក- ស្រង់ទឹក វេរចង្ហាន់

៧. កិច្ចឧទ្ទិសផល

បណ្តាកិច្ចទាំង ៧ថ្នាក់នេះ កិច្ចថ្នាក់ទី ២-៣-៤-៥ នឹងទី ៧ ដូចកិច្ចក្នុងពិធីចម្រើនព្រះបរិត្ត នឹងសង្ឃទាន ប្លែកតែថ្នាក់ទី ១ នឹងទី ៦ ។ ដូច្នេះថ្នាក់ទី ២-៣-៤-៥ នឹងទី ៧ សូមយកតាមបទ័យក្នុងពិធីចម្រើនព្រះ-បរិត្តនឹងសង្ឃទានឯណោះចុះ ។ ទីនេះសូមពណ៌នាតែកិច្ចថ្នាក់ទី ១ នឹង ៦

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ដូចតទៅ÷

## ថ្នាក់ទី ១ កិច្ចធ្វើសាដក

សាដក ប្រែថា សំពត់ង្ងួត ។ សំពត់នេះ សម័យបុរាណគេយកទេស ឯកមកធ្វើ បណ្ដោយ ១ម៨០ យ៉ាងខ្លី ២ម០០ យ៉ាងវែង គេដេរលិនជាយ ហើយជ្រលក់ពណ៌លឿងដូចស្បង់ចីពរ ហាលថ្ងៃឱ្យស្ងួតអ៊ុតឱ្យរាបស្មើ ហើយ គេជីបធ្វើជាផ្កាឈូក ឬផ្លែម្នាស់មានស្លឹក រួចគេខ្ចប់ដោយក្រដាសភ្លឺជាមួយ នឹងបរិក្ខារឯទៀត គឺទៀនធូប ស្លា តែ បារី ឈើគូស ច្រាស់ដុសធ្មេញ ថ្នាំដុសធ្មេញ សៀវភៅធម៌ សៀវភៅសរសេរ ខ្មៅដៃ ទឹកខ្មៅ ដងប៉ាកកា ព្រមទាំងស្លាប ។ ល ។ បើនិមន្តលោក ៤អង្គ គេខ្ចប់ ៤កញ្ចប់ រួចគេយក ទៅដាក់លនៅមុខព្រះភក្ត្រព្រះសង្ឃក្រោយពីពិធី នមស្សការព្រះរតនត្រ័យ សមាទានសីលចម្រើនព្រះបរិត្ត- ទេសនា (១) ចប់ធម៌ទេសនាគេសូត្រយំ កិញ្ចិខ្ទិសផល ។

## ថ្នាក់ទី ៦ កិច្ចវេរសាដក- ស្រង់ទឹក- វេរចង្ហាន់

កាលសូត្រព្រះបរិត្ត- ទេសនាពីល្ងាចរួចហើយ ព្រឹកឡើងពេលម៉ោង ៩ ដែលព្រះសង្ឃនិមន្តមកដល់ហើយ ក្រោយពីប្រគេនលោកឆាន់ភេសជ្ជៈ មានតែស្លា ជាដើមមក គេនាំគ្នានមស្សការព្រះរតនត្រ័យសមាទានសីល ហើយអ្នកដើមការបុណ្យ ឬអ្នកតំណាងនមោ ៣បទ ហើយនាំវេរសាដក ៣ លើក :

(១) ពាក្យអារាធនាទេសនា សូមយកតាមពិធីបុណ្យកឋិន ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


លើកទី ១ ថា :

មយំ ភន្តេ ឥមានិ សាដកានិ សបរិវារានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ សាដកានិ សបរិវារានិ បដិគ្គណ្ហតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវសាដកទាំងឡាយ ព្រមទាំងបរិវារនេះមកដាក់លំទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើនសូមព្រះសង្ឃទទួលយកនូវសាដកទាំងឡាយ ព្រះទាំងបរិវារនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង ជាគម្រប់ពីរដងផង ។

ប្រែលើកទី ៣ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បពិត្រព្រះ ។ ល ។ ទៅហោង ជាគម្រប់បីដងផង ។

វេររួចហើយ គេកាន់សំពត់សាដកនឹងបរិវារទាំងនោះចូលទៅប្រគេនលោក (១) លោកទទួលហើយ សូត្រអនុមោទនាអនុមោទនាហើយ ឧបាសកសូត្រយំកិញ្ចិឧទ្ទិសផល ហើយលោកយកសំពត់សាដកស្រង់ទឹក នៅបន្ទប់ដែលបាំងជិតល្អ ដែលមានទឹកអប់ផ្កាម្លិះឬកូឡាបយ៉ាងក្រអូបឈ្ងុយឈ្ងប់ ។ ឧបាសកអ្នកដើមការបុណ្យនឹងញាតិមិត្ត គេចូលទៅដុសក្អែលលោកដោយស្និទ្ធស្នាលយ៉ាងរីករាយ ក្រោយពីស្រង់ទឹកព្រះសង្ឃ គេអញ្ជើញមាតាបិតាជីដូនជីតាមកផ្ចិត ហៅកូនចៅមកដុសក្អែលយ៉ាងសប្បាយគ្រប់គ្នា (អ្នកខ្លះគេនិមន្តព្រះពុទ្ធរូបប្រាក់ឬថ្មមកស្រង់ផង)

កាលស្រង់ហើយលោកនិមន្តទៅគង់លើអាសនៈវិញ ឧបាសកគប្បីនាំយកចង្ហាន់មករៀប ១ តុឬគ្រប់តុ នៅមុខព្រះភក្ត្រព្រះសង្ឃ រួចអ្នកដើមបុណ្យឬតំណាងគប្បីនាំវេរ (២) ប្រគេនលោក កាលលោកទទួល លោកសូត្រអនុមោទនាហើយ ឧបាសកគប្បីសូត្រយំកិញ្ចិឧទ្ទិសផល (១) ជាកិច្ចបង្ហើយបុណ្យ ។

ចប់ពិធីបុណ្យវេរសាដកត្រឹមប៉ុណ្ណោះ ។

---

(១) ចំណែកខាងបច្ច័យគប្បីបវារណាដោយវាចាតាមពាក្យជាគម្រូនៅក្នុងពិធីចម្រើនព្រះបរិត្តឯណោះ ។

(២) ពាក្យវេរចង្ហាន់ សូមយកតាមពាក្យវេរ ក្នុងពិធីបុណ្យសង្ឃទានក៏បានសង្ឃភត្តក៏បានតាមស្ម័គ្រ ។

(១) ពាក្យឧទ្ទិសផលសូមយកតាមពាក្យឧទ្ទិសក្នុងពិធីចំរើនព្រះបរិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


# ពិធីវេរគ្រប់យ៉ាង

ឧបាសកឧបាសិកាអ្នកមានសទ្ធាជ្រះថ្លា ត្រូវការធ្វើបុណ្យទានមានភត្ត១៤ ជាដើម ដែលមានពិធីវេរ គប្បីមើលឱ្យយល់សេចក្តី នឹងទន្ទេញបាលីវេរឱ្យចាំមាត់ តាមសំណៅដែលបានត្រាទុកខាងមុខនេះ :

## ភត្ត ១៤ប្រការ

១• សង្ឃភត្តំ នូវភត្តដល់ព្រះសង្ឃ

២• ឧទ្ទេសភត្តំ នូវភត្តដល់ភិក្ខុ ១អង្គ ឬ ២អង្គ ឬ ៣អង្គជាដើម តាមពាក្យដែលសង្ឃសំដែងអោយ ។

៣• និមន្តនភត្តំ នូវភត្តដល់ភិក្ខុដែលខ្លួននិមន្តមក ។

៤• សលាកភត្តំ នូវភត្តដល់ភិក្ខុទាំងឡាយដែលខ្លួនសរសេរឈ្មោះក្នុងស្លាកហើយចាប់ ។

៥• បក្ខិករភត្តំ នូវភត្តដល់ភិក្ខុសង្ឃក្នុងសុក្កបក្ខ គឺចំណែកខាងខ្នើត ឬកាឡបក្ខ គឺចំណែកខាងរនោច តែក្នុង ១បក្ខ ប្រគេនតែ ១ថ្ងៃ មិនមានកំណត់ថ្ងៃណា ។

៦• ឧបោសថិកភត្តំ នូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ ឧបោសថកាល ។

៧• បាដិបាទិកភត្តំ នូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ ១កើត ឬ១រោច ។

៨• អាគន្តុកភត្តំ នូវភត្តដល់ភិក្ខុសង្ឃដែលទើបមកដល់ថ្មី ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៩. គមិកភត្ត នូវភត្តដល់ភិក្ខុសង្ឃដែលមានដំណើរទៅកាន់ទីណាមួយ ។

១០. គិលានភត្តំ នូវភត្តដល់ភិក្ខុសង្ឃដែលមានជម្ងឺ ។

១១. គិលានុបដ្ឋាកភត្តំ នូវភត្តដល់ភិក្ខុសង្ឃជាអ្នករក្សាជម្ងឺភិក្ខុសាមណេរផងគ្នា ។

១២. និច្ចភត្តំ នូវភត្តដែលត្រូវប្រគេនជានិច្ចដល់ភិក្ខុសង្ឃ ។

១៣. កុដិកភត្តំ នូវភត្តដល់ភិក្ខុសង្ឃនៅទីលំនៅមានកុដិជាដើម (ភត្តនេះ ហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ) ។

១៤. វារភត្តំ នូវភត្តដល់ភិក្ខុសង្ឃដោយចាត់ចែងជាវេន ។

ភត្តទាំង ១៤ ប្រការនេះ បើទាយកត្រូវការវេរភត្តណាមួយ ត្រូវដាក់ឈ្មោះភត្តនោះ ក្នុងបាលីវេរ ត្រង់វង់ក្រចក (...) យ៉ាងនេះចុះ ។

## ពិធីវេរភត្ត ១៤

មុនដំបូង អ្នកនាំវេរ គប្បីនាំសូត្រនមស្សការ ថា :

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

បន្ទាប់មក នាំវេរ ៣លើក

លើកទី ១ ថា :

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (...) -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


(១) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ (...) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។

លើកទី ២ ថា :

ទុតិយម្បិ អយំ នោ ។ ល ។ និស្សន្ទេន ។

លើកទី ៣ ថា :

តតិយម្បិ អយំ នោ ។ ល ។ និស្សន្ទេន ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានឹងបិតាជាដើម យើងខ្ញុំទាំងឡាយវេរ នូវ (...) នេះ ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏គុណទាំងឡាយមានមាតានឹងបិតាជាដើមនោះ សំគាល់នូវ (...) នេះ ជាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរំដោះចាកទុក្ខទាំងពួងឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ៣ប្រការ

---

(១) ត្រង់វង់ក្រចកនេះ ក្នុងភត្តទាំង ១៤ ដែលរាប់ខាងដើមនេះ បើត្រូវការវេរភត្តណាដូច សង្ឃភត្តជាដើម ត្រូវដាក់ថា សង្ឃភត្តំ ។ ល ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្ដីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនមកមិនដាច់នេះហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ នេះហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី៣ ថា :

បពិត្រព្រះ ។ ល ។ នេះហោង ។ អស់វារៈបីដងផង ។

## វេរបច្ច័យ ៤ ដល់សង្ឃ

លើកទី ១ ថា :

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤នេះ មកដាក់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរបច្ច័យ ៤ដល់ភិក្ខុ ១អង្គ

លើកទី ១ ថា :

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះករុណាដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ ៤នេះ មកដំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះករុណាដ៏

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


មានអាយុ បពិត្រព្រះករុណាដ៏ចម្រើនសូមព្រះករុណាទទួលយក នូវបច្ច័យទាំងឡាយ៤នេះ ដើម្បីសេចក្ដីចម្រើន ដើម្បជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះករុណា។ល។ ហោង។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះករុណា។ល។ ទៅហោង។អស់វារៈបីដងផង ។

## វេរកឋិនទាន

លើកទី ១ ថា :

ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។

លើកទី ២ ថា :

ទុតិយម្បិ ឥមំ ។ល។ ទេម ។

លើកទី ៣ ថា :

តតិយម្បិ ឥមំ ។ល។ ទេម ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរប្រគេនដល់ព្រះសង្ឃ ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃង ។ល។ ដល់ព្រះសង្ឃ ។ អស់វារៈពីរដងផង

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រៃលើកទី ៣ ថា :

បពិត្រព្រះគម្តែង ។ល។ ដល់ព្រះសង្ឃ ។ អស់វារៈបីដងផងនឹង វេរថា :

ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស ទេម ។

ដូច្នេះក៏បាន ប្រៃដូចគ្នា ។

## វេរបរិក្ខារជាបរិវារកឋិន

លើកទី ១ ថា :

យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេម

លើកទី ២ ថា :

ទុតិយម្បិ យេនម្ហាកំ ។ល។ ទេម

លើកទី ៣ ថា :

តតិយម្បិ យេនម្ហាកំ ។ល។ ទេម

លើកទី ១ ថា :

បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ វីកឋិនន៏យើងខ្ញុំទាំងឡាយ គឺជា ម្ចាស់អង្គណាបានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយសូមវេរ ប្រគេនដល់លោកម្ចាស់អង្គនោះ។

ប្រៃលើកទី ២ ថា :

បពិត្រព្រះគម្តែង ។ល។ អង្គនោះ ។ អស់វារៈពីរដងផង ។

ប្រៃលើកទី ៣ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បពិត្រព្រះគម្តែង ។ល។ អង្គនោះ ។ អសវ្វារះបីដងផង ។

សំពត់ ៧ប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកអោយជាសំពត់សមណបរិក្ខារនោះ គឺសំពត់ត្រៃចីវរ ១ សំពត់សម្រាប់ងូតទឹកភ្លៀង ១ សំពត់សម្រាប់ក្រាលអង្គុយ ១ សំរាប់ក្រាលជាកំរាល ១ សំពត់សំរាប់គ្របបូសឬគ្របដំបៅ ១ សំពត់សំរាប់ជូតមុខតឹកខ្សែង ១ សំពត់តូច ឬ ធំជាងប្រមាណ ហៅថាសំពត់បរិក្ខារចោឡៈ ១ បញ្ចុលសំពត់ សម្រាប់ស្រង់ទឹក ១ សំពត់ចំណាំវស្សា ១ នឹងសំពត់អច្ចេកចីវរ ១ ថែមជា ១០ ។

សំពត់ទាំង ១០ ប្រការនេះ បើទាយកមានប្រាថ្នានឹងវេរសំពត់ណាមួយដល់សង្ឃហើយបើសំពត់នោះមានតែ ១ ត្រៃឬ ១ ផ្ទត់ ត្រូវដាក់ឈ្មោះនោះជាបាលីឯកវចនៈ ក្នុងពាក្យវេរដូចមានសំណៅទុកជាបែបទាំង ១០ យ៉ាងខាងមុខនេះ :

១- ឥមំ តិចីវរំ នូវត្រៃចីវរនេះ

២- ឥមំ វស្សិកសាដិកំ នូវសំពត់សំរាប់ងូតទឹកភ្លៀងនេះ

៣- ឥមំ និសីទនំ នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ

៤- ឥមំ បច្ចត្ថរណំ នូវសំពត់សម្រាប់ក្រាលនេះ

៥- ឥមំ គណ្ឌុប្បដិច្ឆាទឹ នូវសំពត់សម្រាប់គ្របបូស ឬ ដំបៅនេះ

៦- ឥមំ មុខបុញ្ឆនចោឡំ នូវសំពត់សម្រាប់ជូតមុខតឹកខ្សែងនេះ

៧- ឥមំ បរិក្ខារចោឡំ នូវសំពត់តូច ឬ ធំជាងប្រមាណ ជាបរិក្ខារនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


៨- ឥមំ បរិសាវនំ នូវសំពត់សម្រាប់ត្រងទឹកនេះ

៩- ឥមំ វស្សាវាសិកំ នូវសំពត់ចំណាំវស្សានេះ ។

១០- ឥមំ អច្ចេកចីវរំ នូវសំពត់អច្ចេកចីវរនេះ ។

ក្នុងបណ្តាសំពត់ទាំង ១០ ប្រការនេះ បើត្រូវការវេរសំពត់ណាមួយ ត្រូវយកឈ្មោះសំពត់ដែលបានសំណៅ ទុកជាបែបបទ មកដាក់ជាបាលីសម្រាប់វេរ ត្រង់កន្លែងដែលមានវង់ក្រចកនោះៗ ដូចខាងក្រោមនេះ :

## វេរត្រៃចីវរ

លើកទី ១ ថា :

មយំ ភន្តេ ឥមំ (តិចីវរំ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ល។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ល។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវ (ត្រៃចីវរ)នេះ មកដឹកលំទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវ (ត្រៃចីវរ)នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លែងសង្ឃ ។ល។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។ មួយយ៉ាងទៀត សំពត់ទាំង ១០ ប្រការនេះ បើទាយកត្រូវការវេរសំពត់ណាមួយដល់សង្ឃ ហើយបើសំពត់នោះមានច្រើនឬច្រើនផ្ទត់ ត្រូវដាក់ឈ្មោះសំពត់នោះជាបាលីពហុវចនៈបញ្ចូលក្នុងពាក្យវេរ ដូចមានសំណៅទុកជាបែបទាំង ១០ យ៉ាងខាងក្រោមនេះ÷

១. ឥមានិ តិចីវរានិ នូវសំពត់ត្រៃចីវរទាំងឡាយនេះ

២. ឥមា វស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ ។

៣. ឥមានិ និសីទនានិ នូវសំពត់ទ្រាប់អង្គុយទាំងឡាយនេះ ។

៤. ឥមានិ បច្ចត្ថរណានិ នូវសំពត់កម្រាលទាំងឡាយនេះ

៥. ឥមាន គណ្ឌុប្បដិច្ឆាទីនិ នូវសំពត់សម្រាប់គ្របបូសឬដំបៅទាំងឡាយនេះ ។

៦. ឥមានិ មុខបុញ្ឆនចោឡានិ នូវសំពត់សម្រាប់ជូតមុខទាំង-

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ឡាយនេះ ។

៧. ឥមានិ បរិក្ខារចោឡានិ នូវសំពត់បរិក្ខារចោឡៈទាំងឡាយនេះ

៨. ឥមានិ បរិសាវនានិ នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ

៩. ឥមា វស្សាវាសិកាយោ នូវសំពត់ចំណាំវស្សាទាំងឡាយនេះ

១០. ឥមានិ អច្ចេកចីវរានិ នូវសំពត់អច្ចេកចីវរទាំងឡាយនេះ

ក្នុងបណ្តាសំពត់ទាំង ១០ ប្រការនេះ បើត្រូវការវេរសំពត់ណាមួយ ត្រូវយកឈ្មោះសំពត់ទាំងនុ៎ះ មកដាក់ជាបាលីសម្រាប់វេរដូចខាងមុខនេះ ត្រង់កន្លែងដែលមានវង់ក្រចកទុកស្រាប់នេះចុះ ។

### វេរសំពត់សម្រាប់ងូតទឹកភ្លៀង

លើកទី ១ ថា :

មយំ ភន្តេ ឥមា (វស្សិកសាដិកាយោ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមា (វស្សិកសាដិកាយោ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានទាំ នូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះ មកដឹកយ៉េទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរសង្ឃទាន

លើកទី ១ ថា :

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយាទីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រែលើកទី ១ ថា :

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែង នូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនឹងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវវត្ថុទាំងឡាយ មានបង្អែមនឹងចម្អាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

បពិត្រព្រះគម្ពែងសង្ឃ ។ ល ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះគម្ពែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរគណាទាន

លើកទី ១ ថា :

បយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សជ្ជេត្វា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទភោជនីយាទីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ប្រែលើកទី ១ ថា :

បពិត្រព្រះករុណា ទាំងឡាយដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនឹងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់លោកម្ចាស់អ្នកមានសីលទាំងឡាយ បពិត្រព្រះករុណាទាំងឡាយ បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់ អ្នកមានសីលទាំងឡាយទទួលយក នូវវត្ថុទាំងឡាយ មានបង្អែមនឹងចម្អាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះករុណាទាំងឡាយ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះករុណាទាំងឡាយ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរបាដិបុគ្គលិកទាន

លើកទី ១ ថា :

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សជ្ជេត្វា សីលវតោ ទេម សាធុ ភន្តេ សីលវា ឥមានិ ខាទនីយភោជនីយា-ទីនិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះករុណាដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយមានខាទនីយភោជនីយាហារ គឺបង្អែម នឹងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះករុណាអ្នកមានសីល បពិត្រព្រះករុណាដ៏ចម្រើន សូមលោកម្ចាស់អ្នកមានសីលទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនឹងចម្អាបជាដើម ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះករុណា ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះករុណា ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរអង្ករ

លើកទី ១ ថា :

មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ តណ្ឌុលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ លេ ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃង សង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវអង្ករទាំងឡាយនេះ មកដាក់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវអង្ករទាំងឡាយនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេរផ្លែឈើផ្សេង

លើកទី ១ ថា :

មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហាតុ អម្ហាកំ -

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ទីយេវត្ថុំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវផ្លែឈើផ្សេងៗ ទាំងឡាយនេះ មកដឹកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវផ្លែឈើផ្សេងៗ ទាំងឡាយនេះ ដើម្បីសេចក្ដីចម្រើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## វេររោងឧបោសថ គិរិហារ

លើកទី ១ ថា :

មយំ ភន្តេ ឥមំ (ឧបោសថគារំ ) ការេត្វា ឧបោសថបវារ-ណោទិសង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ភន្តេ ភិក្ខុសង្ឃោ ឥមំ (ឧបោសថាគារំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើនូវ (រោងសម្រាប់ធ្វើឧបោសថ) នេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្មជាដើម បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវ (រោងសម្រាប់ធ្វើឧបោសថ) នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះតម្លៃងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ពិធីវេរគ្រឿងសេនាសនៈ

វេរសាលា ថា

ឥមំ សាលំ នូវសាលានេះ

វេរកប្បិយកុដិ ថា

ឥមំ កប្បិយកុដឹ នូវកប្បិយកុដីនេះ

វេរកុដិតូច ឬតូប ថា

ឥមំ កុដឹ នូវកុដីតូច ឬតូបនេះ

វេរកុដិធំថា

ឥមំ វិហារំ នូវកុដិធំនេះ

វេរបង្គន់ ថា

ឥមំ វច្ចកុដឹ នូវបង្គន់នេះ

បើត្រូវការវេរសាលាក្តី កប្បិយកុដិក្តី កុដិតូច ឬតូបក្តី កុដិធំក្តី បង្គន់ក្តីទាំង ៥យ៉ាងនេះ នឹងវេររបស់ណាមួយ ត្រូវយករបស់នោះ ទាំងបាលី ទាំងសម្រាយ មកដាក់ត្រង់កន្លែងវង់ក្រចកនោះ ហើយសូត្រវេរចុះ ។

វេរគរុភណ្ឌ

បើកទី ១ ថា :

មយំ ភន្តេ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


ហិតាយ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវគរុភណ្ឌនេះ មកដឹកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ភិក្ខុសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយក នូវគរុភណ្ឌនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ប្រែលើកទី ២ ថា :

បពិត្រព្រះព្រះគម្តែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះគម្តែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

## ពិធីវេរគ្រឿងភេសជ្ជៈ

## វេរទឹកឃ្មុំ

លើកទី ១ ថា :

**មយំ ភន្តេ ឥមំ (មធុំ) ឥធានេត្វា ភិក្ខុ សង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មធុំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ -**

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


អត្ថាយ ហិតាយ សុខាយ ។

លើកទី ២ ថា :

ទុតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

លើកទី ៣ ថា :

តតិយម្បិ មយំ ភន្តេ ។ ល ។ សុខាយ ។

ប្រែលើកទី ១ ថា :

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវ (ទឹកឃ្មុំ) នេះ មកដំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវ (ទឹកឃ្មុំ) នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំ ។

ប្រែលើកទី ២ ថា :

បពិត្រព្រះគម្ពែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈពីរដងផង ។

ប្រែលើកទី ៣ ថា :

បពិត្រព្រះគម្ពែងសង្ឃ ។ ល ។ ទៅហោង ។ អស់វារៈបីដងផង ។

វេរប្រេងថា :

ឥមំ តេលំ នូវប្រេងនេះ

វេរទឹកអំពៅថា :

ឥមំ ផាណិតំ នូវទឹកអំពៅនេះ

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer


វេរទឹកត្នោតថា :

ឥមំ តាលោទកំ នូវទឹកត្នោតនេះ

វេរថ្នាំរម្ងាប់រោគ ថា :

ឥមំ គិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្សឈឺនេះ ។

បើត្រូវការវេរប្រេងក្តី ទឹកអំពៅក្តី ទឹកត្នោតក្តី ថ្នាំរក្សានូវជម្ងឺក្តី ទាំង ៤ នេះ របស់ណាមួយ ត្រូវយកឈ្មោះរបស់នោះ ទាំងបាលីទាំងសម្រាយ មកដាក់ត្រង់កន្លែង ដែលវង់ក្រចកនុំះហើយសូត្រវេរចុះ ។

❀❀❀❀

❀❀

www.budinst.gov.kh www.elibraryofcambodia.org

www.facebook.com/7khmer
www.budinst.gov.kh www.elibraryofcambodia.org